# ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២២

## សម្តេចនាយករដ្ឋមន្ត្រី៖ កម្ពុជាបានបោះជំហានទៅមុខទៅមុខក្នុងឆន្ទៈរួមគ្នាលុបបំបាត់ អំពើហិង្សា និងអំពើរំលោភបំពានគ្រប់រូបភាពមកលើកុមារ

http://freshnewsasia.com/ 2022-05-31 12:48pm

**(ភ្នំពេញ)៖** ប្រមុខនៃរាជរដ្ឋាភិបាលកម្ពុជា សម្តេចតេជោ ហ៊ុន សែន និងជាប្រធានកិត្តិយសក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីកុមារ បានគូសបញ្ជាក់ថា ក្នុងនាមជាសមាជិកភាពជាដៃគូសកល ដើម្បីលុបបំបាត់អំពើហិង្សាលើកុមារ កម្ពុជាបានបោះជំហានទៅមុខ ក្នុងឆន្ទៈបង្ហាញការប្តេជ្ញាចិត្តរួមគ្នាលុបបំបាត់ អំពើហិង្សាលើកុមារ និងអំពើរំលោភបំពានគ្រប់រូបភាពមកលើកុមារ។ តាមរយៈសារលិខិតក្នុងឱកាសខួបលើកទី៧៣ ទិវាកុមារអន្តរជាតិ ១ មិថុនា ខួបលើកទី២១ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២ មិថុនា និងទិវាកុមារកម្ពុជា ឆ្នាំ២០២២ នាយករដ្ឋ មន្ត្រីនៃកម្ពុជា បានថ្លែងថា «**ក្នុងនាមជាសមាជិកភាពជា ដៃគូសកលដើម្បីលុបបំបាត់អំពើហិង្សាលើកុមារ កម្ពុជាយើងបានបោះជំហានទៅមុខក្នុងឆន្ទៈបង្ហាញការប្តេជ្ញាចិត្តរួមគ្នាលុបបំបាត់អំពើហិង្សាលើកុមារ និងអំពើរំលោភបំពានគ្រប់រូបភាពមកលើកុមារ សំដៅធ្វើឱ្យកាន់តែប្រសើរឡើងនូវការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ**»។

សម្តេចតេជោ ហ៊ុន សែន បានបញ្ជាក់ថា កម្ពុជាបានក្លាយជាប្រទេសក្នុងបណ្តាប្រទេសអាស៊ាន ដែលត្រូវបានជ្រើសរើសសម្រាប់ការអង្កេតសិក្សាស្រាវជ្រាវ ពីស្ថានភាពអំពើហិង្សាលើកុមារ ដែលមានលក្ខណៈវិទ្យាសាស្ត្រ ក្នុងការកំណត់ពីទំហំ វិសាលភាព ការផ្តល់ភស្តុតាងជាក់លាក់នៃអំពើហិង្សាលើកុមារ ផ្លូវកាយ ផ្លូវចិត្ត និងផ្លូវភេទ ដែលកុមារបានជួបប្រទះ រួមទាំងបញ្ហាប្រឈមនានា។ **«នាពេលថ្មីនេះ កម្ពុជាបានសម្រេចលទ្ធផលដ៏ធំៗជាច្រើនសម្រាប់កុមារកម្ពុជា ដែលរួមមានការអនុម័ត និងដាក់ឱ្យអនុវត្តផែនការប្រតិបត្តិការបង្ការទប់ស្កាត់ ការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ តាមប្រព័ន្ធអនឡាញ ឆ្នាំ២០២១-២០២៥ ផែនការអនុវត្តគោលនយោបាយជាតិ ស្តីពីប្រព័ន្ធកិច្ចការពារកុមារ ឆ្នាំ២០២១-២០២៥ គោលនយោយស្តីពីការចិញ្ចឹមកូន តាមរយៈឪពុក ម្តាយធម៌ និងសាច់ញាតិ គោលការណ៍ណែនាំស្តីពីកិច្ចការពារកុមារតាមប្រព័ន្ធអនឡាញ និងសេចក្តីព្រាងច្បាប់ស្តីពី កិច្ចការពារកុមារ ម៉្យាងវិញទៀត យើងដឹងហើយថាកិច្ចការពារកុមារ សុវត្ថិភាពរបស់កុមារ ការអនុវត្តសិទ្ធិកុមារគ្រប់ជ្រុងជ្រោយ គឺត្រូវធ្វើឡើងដោយគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ព្រោះរឿងកុមារ ជាការងារពហុវិស័យដែលត្រូវបំពេញរួមគ្នា។ ដូច្នេះ សម្រាប់ថវិកាជាតិរបស់យើង បានផ្តល់ជូននៅគ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធពីថ្នាក់ជាតិ ដល់ថ្នាក់ក្រោមជាតិ»**។ នេះជាការលើកឡើង បន្ថែមរបស់សម្តេចតេជោ ហ៊ុន សែន។

សម្តេចតេជោ ហ៊ុន សែន បានបញ្ជាក់ថា រាជរដ្ឋាភិបាលកម្ពុជា មានចក្ខុវិស័យច្បាស់លាស់ធ្វើយ៉ាងណាឱ្យកុមារ ក្រុមគ្រួសារ និងសហគមន៍ ទទួលបាននូវគុណភាព និងគុណធម៌ នៃការរស់នៅដោយចូលរួមយ៉ាងសកម្មពេញលេញស្មើភាពគ្នាក្នុងតម្លាភាពសង្គម ព្រមទាំងជំរុញឱ្យមានឱកាស ក្នុងការអភិវឌ្ឍគ្រប់វិស័យគ្រប់កម្រិត។ បេសកកម្មរួមគ្នាមួយ គឺជំរុញការចូលរួមពីគ្រប់ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ វិស័យឯកជន អង្គការជាតិ អន្តរជាតិ គ្រួសារសហគមន៍ រួមទាំងកុមារ ដើម្បីធ្វើឱ្យការអនុវត្តច្បាប់ ផែនការយុទ្ធសាស្ត្រជាតិ គោលនយោបាយ បទដ្ឋានគតិយុត្ត និងកម្មវិធីនានា សម្រេចបានប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធផល និងបានបន្តយកចិត្តទុកដាក់ និងលើកកម្ពស់ការអនុវត្តអនុសញ្ញា ស្តីពីសិទ្ធិកុមារ និងច្បាប់អន្តរជាតិពាក់ព័ន្ធ ក្នុងការឆ្លើយតបទៅនឹងតម្រូវការរបស់កុមារ និងការប្តេជ្ញាចិត្តគោរព ការពារ និងបំពេញសិទ្ធិនានាចំពោះប្រជាពលរដ្ឋ ជាពិសេសកុមារដើម្បី រស់នៅក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ សមភាព និងសុវត្ថិភាពស្របតាមរដ្ឋធម្មនុញ្ញ និងគោលការណ៍នីតិរដ្ឋ៕

# ពលករខ្មែរជិត ៧០ នាក់ ដែលកំពុងប្រឈមបញ្ហានៅប្រទេសថៃ ត្រូវបានសមាគមជួយដោះស្រាយ

https://www.postkhmer.com/ មុំ គន្ធា | Publication date 31 May 2022 | 09:36 ICT

**ភ្នំពេញៈ** ពលករខ្មែរជិត ៧០ នាក់ ត្រូវបានសមាគមមិត្តភាពកម្មករនិយោជិតកម្ពុជាប្រចាំប្រទេសថៃហៅកាត់ថា ស៊ីហ្វាត-CFAT ក្នុងតំបន់បានកៅ ស្រុកផាន់ថង ខេត្តឈុនបុរី ជួយដោះស្រាយបញ្ហាដល់ពួកគាត់ដែលក្នុងនោះមានពលករជិត ៤០ នាក់បានចាញ់បោកមេខ្យល់។ មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (សង់ត្រាល់) ឱ្យដឹង នាថ្ងៃទី ៣០ ឧសភា ថា តំណាងអង្គការសង់ត្រាល់ប្រចាំនៅប្រទេសថៃសហការជាមួយសមាជិកសមាគមមិត្តភាពកម្មករនិយោជិតកម្ពុជាប្រចាំប្រទេសថៃ ហៅកាត់ថា ស៊ីហ្វាត-CFAT ក្នុងតំបន់បានកៅ ស្រុកផាន់ថង ខេត្តឈុនបុរី កាលពីថ្ងៃទី ២៩ ឧសភា បានចុះជួយដោះស្រាយបញ្ហាប្រឈមរបស់ពលករចំនួន ៦៧ នាក់ ក្នុងនោះមានពលករ ៣៨ នាក់បានចាញ់បោកមេខ្យល់។

មន្ត្រីទទួលបន្ទុកការពារសិទ្ធិពលករប្រចាំប្រទេសថៃរបស់អង្គការសង់ត្រាល់នៅប្រទេសថៃ លោក លឹង សុផុន ឱ្យដឹងថា កិច្ចសហការចុះទៅអន្តរាគមន៍ និងដោះស្រាយបញ្ហារបស់ពលករខ្មែរនៅប្រទេសថៃ បន្ទាប់ពីមានការស្នើសុំជំនួយអន្តរាគមន៍របស់ពលករខ្មែរជាង ២០ នាក់។ ពួកគេបានស្នើសុំមកអង្គការសង់ត្រាល់ ប្រចាំប្រទេសថៃស្វែងរកដំណោះស្រាយឱ្យបានសមរម្យសម្រាប់ពួកគេ។ លោកបន្តថាៈ «ក្នុងចំណោមពលករ ៦៧ នាក់ដែលអង្គការសង់ត្រាល់បានចុះអន្តរាគមន៍នោះ គឺមានពលករខ្មែរចំនួន ៣៨ នាក់បានចាញ់បោកមេខ្យល់អស់ប្រាក់រហូតដល់ ៧ ០០០ បាតក្នុងម្នាក់ៗដោយមេខ្យល់របស់ពួកគេបានសន្យាថានឹងស្វែងរកការងារឱ្យនៅរោងចក្រផលិតនំប៉័ង ព្រមទាំងរត់ការធ្វើឯកសារបន្តសុពលភាពទិដ្ឋាការ ធ្វើបណ្ណការងារឱ្យបានត្រឹមត្រូវតាមច្បាប់ការងាររបស់ប្រទេសថៃក្នុងតំបន់ឧស្សាហកម្មស្រុកផាន់ថង ខេត្តឈុនបុរី នោះ»។

ពលករខ្មែរទាំង ៣៨ នាក់ ដែលចាញ់បោកមេខ្យល់បានរង់ចាំធ្វើការងារតាមការសន្យារបស់មេខ្យល់រយៈពេលជិត ៣ ខែហើយ។ ប៉ុន្តែមេខ្យល់មិនទទួលខុសត្រូវ និងមិនបានរកការងារឱ្យដល់ពលករដូចជាការសន្យាឡើយ។ នេះបើតាមការបញ្ជាក់ឱ្យដឹងពីលោក លឹង សុផុន។ ជាមួយគ្នានោះ តំណាងអង្គការសង់ត្រាល់ និងក្រុមបណ្ដេញស៊ីហ្វាត-CFAT នឹងសហការជាមួយ មូលនិធិ LPN (មូលនិធិការពារសិទ្ធិពលករអន្តោប្រវេសន៍) ក្នុងប្រទេសថៃបានចុះជួយពលករទាំងនេះដល់កន្លែងពលករស្នាក់នៅក្នុងតំបន់នោះផងដែរ ហើយបានសហការជាមួយមេការដែលធ្វើការប្រចាំរោងចក្រផលិតនំប៉័ង ដើម្បីជួយដោះស្រាយបញ្ហាមួយចំនួនរបស់ពលករខ្មែរ ដែលពាក់ព័ន្ធ។ បើតាមអង្គការសង់ត្រាល់ បន្ទាប់ពីប្រជុំរកដំណោះស្រាយរួច មេការដែលតំណាងរោងចក្រផលិតនំប៉័ងនេះ បានសន្យាទទួលយកការទាមទាររបស់ពលករខ្មែរ ដោយដកប្រាក់គ្រប់ចំនួនដែលបានបង់ទៅឱ្យមេខ្យល់កន្លងមកនោះ យកមកវិញ។ ប្រភពដដែលបានបន្តថា តាមរយៈមេការជាអ្នកបកប្រែតំណាងរោងចក្រនំប៉័ង ក៏បានសន្យាសងលុយត្រឡប់មកវិញគ្រប់ចំនួនក្នុងរយៈពេល ១ សប្ដាហ៍ និងហៅមេខ្យល់មកដោះស្រាយនៅរោងចក្រផងដែរ។

លោកស្រី រស់ សុផានី អភិបាលរងខេត្តបន្ទាយមានជ័យ ថ្លែងនាដើមខែឧសភា ក្នុងពិធីសម្ពោធមជ្ឈមណ្ឌលធនធានពលករទេសន្តរប្រវេសន៍ហៅកាត់ថា MRC ក្នុងក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ថាប្រជាពលរដ្ឋ ក៏ដូចជាពលករខ្មែរ កុំទាប់ជឿលើមេខ្យល់ក្នុងការនាំទៅធ្វើការនៅក្រៅប្រទេស ព្រោះវាជាការខុសច្បាប់ ហើយកិច្ចការងារអ្វីក៏ដោយ គឺត្រូវតែធ្វើដោយស្របច្បាប់ត្រឹមត្រូវទើបមានសុវត្ថិភាព។ យោងតាមរបាយការណ៍របស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈបានឱ្យដឹងថា ប្រជាជនកម្ពុជាជាង ១,៣ លាននាក់ បាននិងកំពុងបម្រើការងារ នៅក្រៅប្រទេសដែលក្នុងនោះពលករខ្មែរធ្វើការច្រើនជាងគេ មាននៅប្រទេសថៃ ម៉ាឡេស៊ី ជប៉ុន និង

សាធារណរដ្ឋកូរ៉េ ហើយក៏បានផ្ញើប្រាក់ប្រមាណជិត ៣ ប៊ីលានដុល្លារអាមេរិក ក្នុង ១ ឆ្នាំៗមកកាន់ប្រទេសកំណើតផងដែរ៕

## សមត្ថកិច្ចកម្ពុជា-ថៃ តាមព្រំដែន ជួបពិភាក្សាដើម្បីរឹតបន្តឹងចំណងមិត្តភាព ទប់ស្កាត់បទល្មើសឆ្លងដែន និងការនាំមនុស្សឆ្លងដែនខុសច្បាប់

http://freshnewsasia.com/ 2022-05-31 12:32pm

**(បន្ទាយមានជ័យ)៖** កងកម្លាំងឈរជើងនៅតាមព្រំដែនកម្ពុជា រួមមាន កម្លាំងនគរបាល និងកម្លាំងយោធាផ្នែកសឹករងស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ នៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២នេះ បានជួបពិភាក្សាជាមួយទាហានឈុនខ្មៅថៃ ដើម្បីរឹតបន្តឹងចំណងសាមគ្គីភាព មិត្តភាព រួមគ្នាទប់ស្កាត់រាល់បទល្មើសឆ្លងដែនគ្រប់ប្រភេទ ជាពិសេសការនាំមនុស្សឆ្លងដែនខុសច្បាប់ និងផ្តល់ព័ត៌មានទៅវិញទៅមក។

កិច្ចពិភាក្សានេះធ្វើឡើងដោយមានការចង្អុលបង្ហាញពីឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ ស្នងការនគរបាលខេត្តបន្ទាយមានជ័យ និងអនុវត្តបទបញ្ជាផ្ទាល់ពីលោកវរសេនីយ៍ឯក សួង សៅ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៥។ ភាគីកម្ពុជា ដឹកនាំដោយលោកវរសេនីយ៍ត្រី រឿម ប៊ុនរិទ្ធ នាយប៉ុស្តិ៍ រួមជាមួយកម្លាំងយោធាផ្នែកសឹករងស្រុកម៉ាឡៃ, លោកវរសេនីយ៍ត្រី ជា រិត មេបញ្ជាការកងអនុសេនាធំទី១។ រីឯភាគីថៃ ដឹកនាំលោកវរសេនីយ៍ត្រី ស៊ុរ៉ាត់ យាន់បួបាន មេបញ្ជាការកងអនុសេនាធំ១៣.០៥ ឈរជើងទល់មុខភូមិសាស្ត្រប៉ុស្តិ៍ក្បាលទំនប់។

សូមបញ្ជាក់ថា កម្លាំងទាំងពីរនឹងខិតខំយកចិត្តទុកដាក់អនុវត្តបន្តតាមការណែនាំរបស់ថ្នាក់ដឹកនាំប្រទេសទាំងពីរ ព្រមទាំងគោរពតាបទបញ្ជាមេបញ្ជាការ និងសហការគ្នាទប់ស្កាត់បញ្ហាបទល្មើសផ្សេងៗ ដែលកើតមានឡើងតាមព្រំដែនកម្ពុជា-ថៃ ឱ្យទទួលបានប្រសិទ្ធភាពខ្ពស់៕

## ទាហានវៀតណាមបាញ់ពលករខ្មែរលីបារីឆ្លងដែនម្នាក់របួស ឯជាង១០នាក់រត់បែកជើងគ្នា

https://kohsantepheapdaily.com.kh/ កំពត៣១ ខែ ឧសភា ឆ្នាំ ២០២២ ម៉ោង ១៤:៤៩

ខេត្តកំពត ៖ កងទាហានវៀតណាមបានបាញ់រះមកលើប្រជាពលរដ្ឋខ្មែរ ដែលកំពុងលីបារី «ហេរ៉ុង» ឆ្លងដែនចំនួន១៤នាក់ កាលពីវេលាម៉ោង០៣ និង៣០នាទីទៀបភ្លឺ ឈានចូលដល់ថ្ងៃទី៣១ ឧសភា នៅចំណុចស្ពានមុខបង្គោលលេខ309 ក្នុងភូមិកោះចំការ ឃុំបឹងសាខាងត្បូង ស្រុកកំពង់ត្រាច ខេត្តកំពត ។

ករណីបាញ់របស់ភាគីវៀតណាម មកលើប្រជាពលរដ្ឋទាំង១៤នាក់ខាងលើ ធ្វើឱ្យពលរដ្ឋម្នាក់ឈ្មោះ ជឿង ហុង ភេទប្រុស អាយុ២០ របួសជើងខាងស្តាំ ។ តាមការអោយដឹងពីយុវជនឈ្មោះ ជឿង ហុង ដែលសម្រាកព្យាបាលនៅគ្លីនិកឯកជនមួយនៅជាប់ច្រកទ្វារអន្តរជាតិព្រែកចាក ក្នុងស្រុកកំពង់ត្រាច បានប្រាប់ឱ្យដឹងនៅព្រឹកថ្ងៃទី៣១ ឧសភា នេះថា ខ្លួនមិនទាន់មានប្រពន្ធទេដោយជាមួយអ្នកភូមិជាច្រើននាក់ បានជញ្ជូនបារីឆ្លងដែនចូលទៅវៀតណាមខ្លួនក៏បានស្ពាយបារីចំនួន២កេះ ស្មើនិងមួយរយសុងដើរឆ្លងទឹកឆ្លងភក់ប្រហែលមួយគីឡូចូលទៅវៀតណាម ។ ភ្លាមនោះ គ្រាន់តែដើរដល់ចំណុចស្ពានបង្គោល309ស្រាប់តែវៀតណាមបានស្រែក ប៉ុន្តែពួកគាត់មិនចេះភាសាវៀតណាម។ តែអ្នកខ្លះទៀតបានដើរឆ្លងស្ពានស្រាប់តែវៀតណាមបានបាញ់មកលើខ្លួនតែម្តងបណ្តាលអោយត្រូវរបួសជើងម្ខាង។ ពេលដៃត្រូវរបួស ខ្លួនបានរត់ចេញពីកន្លែងគ្រោះថ្នាក់ និងអ្នកលីបារីផ្សេងៗទៀតជាង10នាក់រត់បែកគ្នាអស់។ ជនរងគ្រោះបានដើរមកលាងឈាមនៅមិនឆ្ងាយពីកន្លែងកើតហេតុមិនយូប៉ុន្មានខ្លួន ក៏បានជួល

សន្លប់ ហើយមានអ្នករួមដំណើរបើនាក់ទៀតបានសែងយកមកដល់ទូកហើយបានដឹកដល់ផ្ទះនិងយកមកព្យាបាលនៅគ្លីនិកឯកជនមួយនៅព្រៃកចាក ។

នៅព្រឹកថ្ងៃទី៣១ ឧសភា នេះ លោកឧត្តមសេនីត្រីម្នាក់ទទួលបន្ទុកកិចការព្រំដែនបានចូលទៅសាកសួរជនរងគ្រោះនៅក្នុងមន្ទីរពេទ្យ។ លោកឧត្តមសេនីត្រីរូបនោះនិយាយថា ករណីបាញ់នោះសង្ស័យជាគ្រាប់កាំភ្លើងកែច្នៃ។ ទោះជាថា គ្រាប់កាំភ្លើងកែច្នៃអ្វី ក៏ដូចនគរបាលខេត្តកំពតបានចូលទៅវៀតណាម ហើយកាលពីព្រឹកមិញ ព្រោះបាញ់មកលើប្រជាពលរដ្ឋអ្នកលីបារីឆ្លងដែនចំនួន៤គ្រាប់។

## នៅព្រឹកថ្ងៃអង្គារ អាជ្ញាធរស្រុកសំពៅលូន បន្តទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ពីប្រទេសថៃ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ

https://gdlf-kh.com/ 2022/05/31/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅវេលាម៉ោង០៧និង០០នាទី នាថ្ងៃអង្គារ ១កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពាព្រំដែនគោក លេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍គីឡូ១៣ ចំនួន០៣នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក ម៉ឹង-ម៉េត (នាយប៉ុស្តិ៍) សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូនចំនួន០៣នាក់ ដឹកនាំដោយលោកនាយចំណង់ ជា យ៉ាន (មេបញ្ជាការកងអនុសេនាតូច) កម្លាំងយោធាវរសេនាតូច៥៣៣ ចំនួន០៣នាក់ ដឹកនាំ ដោយលោកអនុសេនីយ៍ឯក ពៅ-ចំរើន (មេបញ្ជាការរងកងអនុសេនាធំ) បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន១លើក សរុបចំនួន៣០នាក់ ស្រី១៤នាក់ ក្មេង៧នាក់ ក្មេងស្រី៣នាក់ ។

ក្រោយពីទទួលបាន កម្លាំងយើងបានធ្វើកត់ឈ្មោះ ចុះកំណត់ហេតុប្រចាំថ្ងៃ អប់រំណែនាំ រួចបានប្រគល់បងប្អូនទាំងអស់ឱ្យទៅក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូន ធ្វើការពិនិត្យ និងស្ទ័នប័ណ្ណចាក់វ៉ាក់សាំងចេញត្រឹមត្រូវទាំងអស់ បន្ទាប់មកក្រុមគ្រូពេទ្យបានអនុញ្ញាតឲ្យបងប្អូនត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួន។

# ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២២

## កម្ពុជាផ្តល់ប័ណ្ណការងារដល់ពលករបង់ក្លាដែស ៤០០នាក់ ក្នុងនោះទទួលថែទាំសុខភាព និងរបបហានិភ័យការងារ

https://kohsantepheapdaily.com.kh/ ភ្នំពេញ០១ ខែ មិថុនា ឆ្នាំ ២០២២ ម៉ោង ១០:៥៩

រាជធានីភ្នំពេញ ៖ មកដល់ពេលនេះពលករបង់ក្លាដែសប្រមាណ៤០០នាក់ ដែលទទួលបានប័ណ្ណការងារពីក្រសួងការងារកម្ពុជាដោយទទួលបាននូវការថែទាំសុខភាព និងរបបហានិភ័យការងារពីបេឡាជាតិរបបសន្តិសង្គម (ប.ស.ស) ដូចកម្មករនិ យោជិតរបស់កម្ពុជាដែរ ។ នេះបើរដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ។ ការបញ្ជាក់បែបនេះ ត្រូវបានធ្វើឡើង នាឱកាសឯកឧត្តមបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានអនុញ្ញាតឲ្យលោក មហាម៉េដ អាប់ឌុល ហ៊ី ឯកអគ្គរដ្ឋទូតសាធារណរដ្ឋប្រជាមានិតបង់ក្លាដែសប្រចាំ

កម្ពុជាចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ នៅព្រឹកថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ នាទីស្តីការក្រសួងការងារ ។ ឯកឧត្តមរដ្ឋមន្ត្រីក៏បានលើកឡើងថា កម្ពុជា-បង់ក្លាដែស បានប្តេជ្ញាបន្តពង្រឹងនូវកិច្ចព្រមព្រៀងលើវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាមួយគ្នាទៀត ខណៈកិច្ចព្រមព្រៀងលើអនុស្សរណៈនៃការយោគយល់គ្នា (MOU) រវាងប្រទេសទាំងពីរ ជិតផុតសុពលភាពហើយនោះ ។ ឯកឧត្តម អ៊ិត សំហេង បញ្ជាក់ថា ដំណើរទស្សនកិច្ចរបស់ឯកឧត្តមអគ្គរដ្ឋទូត និងឯកឧត្តមរដ្ឋមន្ត្រី សុខុមាលភាពជនបរទេស និងការងារនៅបរទេសបង់ក្លាដែស ដែលបានដឹកនាំគណៈប្រតិភូមកកាន់កម្ពុជាពេលនេះ គឺជាការបញ្ជាក់ពីទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការល្អរវាងប្រទេសយើងទាំងពីរ ។ ឯកឧត្តមបញ្ជាក់ថា ទូទាំងពិភពលោកក៏ដូចជា ប្រទេសយើងទាំងពីរ បានឆ្លងកាត់នូវការលំបាកដោយសារកូវីដ-១៩ ដូចៗគ្នា ប៉ុន្តែមកដល់ពេលនេះ ដោយសារប្រសិទ្ធភាពនៃវ៉ាក់សាំងរួមនឹងវិធានការសុខាភិបាល បានធ្វើឲ្យស្ថានភាពជំងឺកូវីដ-១៩ មានសភាពស្រាកស្រាល ហើយកម្ពុជាបានកំពុងស្តារនូវសង្គមសេដ្ឋកិច្ចឡើងវិញ តាមគន្លងថ្មី ។ សម្រាប់វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈកម្ពុជា-បង់ក្លាដែស មានអនុស្សរណៈនៃការយោគយល់គ្នា(MOU) តាំងពីឆ្នាំ២០១៧មកម្ល៉េះ ក្រុមការងារបច្ចេកទេសបានធ្វើកិច្ចការស្របទៅនឹងកិច្ចព្រមព្រៀងជាមួយគ្នានេះ ដោយសារកូវីដ-១៩ ធ្វើឲ្យអាក់ខានរយៈពីរឆ្នាំ ហើយថ្ងៃនេះយើងមានឱកាសពិភាក្សាដើម្បីបន្តកិច្ចសហប្រតិបត្តិការនេះជាមួយគ្នា ។

ចំណែក លោកមហាម៉េដ អាប់ឌុល ហ៊ី រីករាយចំពោះកិច្ចសហប្រតិបត្តិការជាមួយកម្ពុជាលើវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនេះ ភាគីទាំងពីរនឹងវិលត្រឡប់មកអនុវត្តន៍កិច្ចការងារដែលបានព្រមព្រៀងគ្នាស្របទៅនឹងMOU ។ នៅក្នុងដំណើរចុះទស្សនកិច្ចរបស់លោកអគ្គរដ្ឋទូត ដែលបានចុះជួបផ្ទាល់ជាមួយជនជាតិបង់ក្លាដែសដែលកំពុងបម្រើការងារនៅក្នុងប្រទេសកម្ពុជាលើផ្នែកសេវាកម្ម សំណង់ ភោនីយដ្ឋាន ធនាគារជាដើមនោះ ឃើញថា ពលរដ្ឋបង់ក្លាដែសទទួលបានការគាំពារ និងយកចិត្តទុកដាក់បានយ៉ាងល្អពីកម្ពុជាដែលអាចឲ្យពួកគេមានលទ្ធភាពបើកដំណើរការអាជីវកម្មរបស់ខ្លួនបានប្រសើរ ។ លោកទូតបញ្ជាក់ថា ប្រទេសយើងទាំងពីរមានទំនាក់ទំនងការទូតចំនួន៣០ឆ្នាំមកហើយ ដោយនៅក្នុងអំឡុងឆ្នាំ១៩៩០ បង់ក្លាដែសបានចូលរួមជាមួយអង្គការសហប្រជាជាតិក្នុងការរក្សាសន្តិភាពនៅកម្ពុជាដែរ ។ នៅក្នុងជំនួបនេះដែរ លោកឯកអគ្គរដ្ឋទូត បានស្នើក្រុមការងារបច្ចេកទេសខាងវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈកម្ពុជាកាន់ទីក្រុងដក្កា ដើម្បីប្រជុំពិភាក្សាជាមួយក្រុមការងារបច្ចេកទេសបង់ក្លាដែសលើកទី២ លើការបន្តMOU ព្រមទាំងបានអញ្ជើញឯកឧត្តមរដ្ឋមន្ត្រីចុះបំពេញទស្សនកិច្ចជាមួយក្រុមការងារកម្ពុជាតែម្តង នៅបង់ក្លាដេស។

ឯកឧត្តម អ៊ិត សំហេង បានថ្លែងអំណរគុណចំពោះការចូលរួមវិភាគ ទានរបស់បង់ក្លាដែស ជាមួយអង្គការសហប្រជាជាតិ នៅលើទឹកដីកម្ពុជាតាំងពីឆ្នាំ១៩៩០ ។ កម្ពុជាមានកិច្ចព្រមព្រៀងសន្តិភាព ការអនុវត្តន៍បានយ៉ាងជោគជ័យនូវនយោបាយឈ្នះឈ្នះរហូតកម្ពុជាមានសុខសន្តិភាពពេញលេញ ដោយចាត់ទុកសន្តិភាពជាអាទិភាពខ្ពស់បំផុត របស់កម្ពុជា មានសន្តិភាព គឺមានអ្វីៗទាំងអស់ ។ ទន្ទឹមនឹងនេះឯកឧត្តមរដ្ឋមន្ត្រី មើលឃើញថា វិស័យការងាររបស់ប្រទេសយើងទាំងពីរប្រហាក់ប្រហែលគ្នា ជាប្រទេសផលិត និងនាំចេញពិសេសវិស័យវាយនភណ្ឌកាត់ដេរ ។ កម្ពុជាមានលក្ខខណ្ឌការងារដែលផ្សាភ្ជាប់ទៅនឹងការនាំចេញកិច្ចព្រមព្រៀង នេះបានផ្តល់ឱកាសដល់អ្នកវិនិយោគ ។ ប្រាក់ឈ្នួលនៅកម្ពុជាមានការតំឡើងខ្ពស់ សម្រាប់ការប្រកួតប្រជែង គឺពិបាកហើយវាក៏ប្រសើរផងដែរសម្រាប់ជីវភាពកម្មករនិយោជិតរបស់កម្ពុជា ។ យើងអាចចែករំលែកបទពិសោធន៍ និងផ្លាស់ប្តូរព័ត៌មានពីគ្នាទៅវិញទៅមកលើវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនេះ ។ ពលករបង់ក្លាដែសប្រមាណ ៤០០ នាក់ដែលទទួលបានប័ណ្ណការងារពីក្រសួងការងារកម្ពុជា ដោយទទួលបាននូវការថែទាំសុខភាព និងរបបហានិភ័យការងារ ពីប.ស.ស ដូចកម្មករនិយោជិតរបស់កម្ពុជាដែរ។

សម្រាប់ការបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ បង់ក្លាដេសមានការរីកចម្រើនខាង បច្ចេកទេសផ្នែកកសិកម្ម ដោយកម្ពុជាផ្តល់អាទិភាពខ្ពស់ទៅលើវិស័យកសិកម្ម កម្ពុជាប្រើប្រា ស់គ្រឿងចក្រស្ទើរតែ១០០ភាគរយទៅហើយ តម្រូវការធនធានមនុស្សសម្រាប់ វិស័យនេះក៏កាន់តែច្រើន ហេតុដូចនេះ កម្ពុជាក៏ត្រូវការឲ្យបង់ក្លាដេសជួយបណ្តុះ បណ្តាលផ្នែកនេះផងដែរ។ សូមជម្រាបជូនដែរថា រាជរដ្ឋាភិបាលកម្ពុជា តំណាងដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចុះMOU ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យការងារ និងបណ្តុះ បណ្តាលវិជ្ជាជីវៈ ជាមួយរដ្ឋាភិបាលបង់ក្លាដេស តំណាងដោយក្រសួងសុខុមា លភាពជនប រទេស និងការងារនៅបរទេស កាលពីថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៧ ដើម្បីរួមគ្នា៖

១.ការគ្រប់គ្រងការជួលពលករទេសន្តរប្រវេសក៍ក្នុងប្រទេសទាំងពីរ។ ២. កិច្ចសហប្រតិបត្តិការក្នុងវិ ស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) ។ ៣. ផ្លាស់ប្តូរព័ត៌មានសម្រាប់ការការពារការជ្រើសរើស និងជួលពលករខុសច្បាប់ ព្រមទាំងការពារ និងប្រយុទ្ធប្រឆាំងការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងការជួញដូរ និង ៤. វិស័យផ្សេងទៀតនៃកិច្ចសហប្រតិបត្តិការទាក់ទងនឹងវិស័យការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈដែលបានព្រមព្រៀងគ្នា៕

## ប៉ូលិស ឃាត់ពលករខ្មែរ ២នាក់ បម្រុងលួចឆ្លងទៅប្រទេសថៃ រកការងារធ្វើ

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ០១ ខែ មិថុនា ឆ្នាំ ២០២២ ម៉ោង ១៩:៣០

បន្ទាយមានជ័យ៖ ប៉ូលិសការពារព្រំដែន បានឃាត់ពលករខ្មែរប្រុស.ស្រី ២នាក់ ដែលបម្រុងលួចឆ្លងទៅប្រទេសថៃ ដើម្បីរកការងារធ្វើ។ ពលករទាំង ២ ត្រូវបានឃាត់ខ្លួន កាលពីម៉ោង ១០យប់ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ នៅភូមិព្រៃគប់ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត។ កម្លាំងនគរបាលការពារព្រំដែនគោកលេខ៩១១ បានប្រាប់ថា នៅពេលឃាត់ពលករខ្មែរ គឺកម្លាំងនគរបាលការពារព្រំដែនគោកលេខ៩១១ បានចេញល្បាតតាមបន្ទាត់ព្រំដែន បានប្រទះឃើញពលករខ្មែរ ២នាក់ នៅក្បែរព្រំដែន ដែលបម្រុងលួចឆ្លងដែនទៅប្រទេសថៃ ដោយខុសច្បាប់។ កម្លាំងបានបញ្ជាក់ថា ក្រោយឃាត់ ជនទាំងពីរត្រូវបាននាំយកមកទីបញ្ជាការដ្ឋានវរៈសេនាតូចនគរបាលការពារព្រំដែនគោកលេខ៩១១ ដើម្បីសាកសួរ។ តាមចម្លើយ ពួកគាត់បម្រុងលួចឆ្លងដែនទៅរកការងារធ្វើនៅប្រទេសថៃ តាមរយៈមេខ្យល់ ក្នុងម្នាក់តម្លៃ ៦.០០០បាត ដោយមេខ្យល់សន្យាជូនទៅរកការងារធ្វើដល់កន្លែង។ កម្លាំងនគរបាលបានបញ្ជាក់ថា ក្រោយធ្វើការសាកសួរហើយ ធ្វើការអប់រំណែនាំ និងធ្វើកិច្ចសន្យា ហើយឱ្យត្រឡប់ទៅស្រុកកំណើតវិញ ហើយកម្លាំងស្រាវជ្រាវរកចាប់ខ្លួនមេខ្យល់៕ ប៊ុន ធឿន

## កម្លាំងនគរបាលការពារព្រំដែនគោក សហការជាមួយកម្លាំងយោធា ទទួលប្រជាពលរដ្ឋវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្រ្តស្រុកសំពៅលូន

https://gdlf-kh.com/ 2022/06/01/ Sam Sophearum បាត់ដំបង

ខេត្តបាត់ដំបង៖ នៅវេលាម៉ោង០៦និង៣០នាទី នាថ្ងៃពុធ ២កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៥ ត្រូវនឹងថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែន កម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោក លេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍គីឡូ១៣ ចំនួន០៣នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក ម៉ឹង ម៉េត (នាយប៉ុស្តិ៍) សហការជាមួយ

កម្លាំងយោធាផ្នែកសឹករងសំពៅលូនចំនួន០៣នាក់ ដឹកនាំដោយលោកនាយចំណង់ ជា យ៉ាន (មេបញ្ជាការកងអនុសេនាតូច) កម្លាំងយោធាវរសេនាតូច៥៣៣ ចំនួន០៣នាក់ ដឹកនាំ ដោយលោកអនុសេនីយ៍ឯក ពៅ-ចំរើន (មេបញ្ជាការរងកងអនុសេនាធំ) បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន១លើក សរុបចំនួន២០នាក់ ស្រី៦នាក់ ក្មេង៤នាក់ ក្មេងស្រី២នាក់ ។ ក្រោយពីទទួលបាន កម្លាំងយើងបានធ្វើកត់ឈ្មោះ ចុះកំណត់ហេតុប្រចាំថ្ងៃ អប់រំណែនាំ រួចបានប្រគល់បងប្អូនទាំងអស់ឱយទៅក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូនធ្វើពិនិត្យ និងស្វែនប័ណ្ណចាក់វ៉ាក់សាំងចេញត្រឹមត្រូវទាំងអស់ បន្ទាប់មកក្រុមគ្រូពេទ្យបានអនុញ្ញាតឲ្យបងប្អូនត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួន ៕

# ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២២

## ៥ ខែដើមឆ្នាំ កម្ពុជាបញ្ជូនពលករ ១៥ ០០០ នាក់ទៅធ្វើការនៅប្រទេសថៃ

https://www.kampucheathmey.com/ ថ្ងៃសៅរ៍ ៤ មិថុនា ២០២២ដោយ Dy Bunnara

រយៈពេល ៥ ខែដើមឆ្នាំ ២០២២ កម្ពុជាបានបញ្ជូនពលករប្រមាណ ១៥.០០០ នាក់ទៅធ្វើការនៅតាមបណ្ដារោងចក្រនានានៅប្រទេសថៃ។

លោក អន ប៊ុនហាក់ ប្រធានសមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជាបានឱ្យដឹងនៅរសៀលថ្ងៃទី០៤មិថុនានេះថា កម្ពុជាបានចាប់ផ្ដើមបញ្ជូនពលករស្របច្បាប់ទៅធ្វើការនៅប្រទេសថៃឡើងវិញនៅក្នុងខែ មករា ឆ្នាំ២០២២ បន្ទាប់ពីប្រទេសថៃបានបើកទទួលពលករបរទេសឡើងវិញ ពិសេសប្រទេសមួយចំនួននៅតាមតំបន់អាស៊ានដូចជា ឡាវ ភូមា និងកម្ពុជា។ នៅក្នុងរយៈពេល៥ខែដើម ឆ្នាំ២០២២នេះ កម្ពុជាបានបញ្ជូនពលករប្រមាណ ១៥.០០០ នាក់ទៅធ្វើការនៅតាមបណ្ដារោងចក្រនានានៅប្រទេសថៃ ដោយពួកគាត់ទៅធ្វើផ្នែករោងចក្រចំណីអាហារ សំណង់ សេវាកម្ម និងកសិកម្ម។ លោក អន ប៊ុនហាក់ បានបន្តទៀតថា អាជ្ញាធរថៃលែងតម្រូវឱ្យពលករខ្មែរទៅធ្វើការនៅប្រទេសរបស់ខ្លួនដោយស្របច្បាប់ ធ្វើចត្តាឡីស័ករយៈពេល៧ថ្ងៃដូចមុនទៀតហើយ ពោលគឺគ្រាន់តែធ្វើតេស្តរហ័សប៉ុណ្ណោះ ដោយសារប្រទេសកម្ពុជាជាប្រទេសដែលមានហានិភ័យទាបបំផុតពោលត្រូវបានគេចាត់ទុកជាប្រទេសមានឆ្លងមេរោគកូវីដ១៩ តិចតួចបំផុតឬគ្មានឆ្លង។

លោក អន ប៊ុនហាក់ បានបន្ថែមថា ក្នុងករណីពលករធ្វើតេស្តរហ័ស អវិជ្ជមាន នឹងអាចចូលទៅធ្វើការបាននៅតាមរោងចក្រនានាតែម្ដង ខណៈកាលពីមុនពលករខ្មែរដែលត្រូវទៅធ្វើការនៅប្រទេសថៃត្រូវធ្វើតេស្តរកជំងឺកូវីដ-១៩ រយៈពេល ៧២ ម៉ោង តាមម៉ាស៊ីន PCR ឬតេស្តរហ័សដែលធ្វើដោយគ្រូពេទ្យជំនាញ ដើម្បីបញ្ជាក់វិញ្ញាបនបត្រថាមិនមានឆ្លងជំងឺកូវីដ-១៩។ ពេលធ្វើការទៅដល់ព្រំដែនថៃត្រូវធ្វើតេស្តម្ដងទៀត ហើយបើលទ្ធផលតេស្តអវិជ្ជមាន ត្រូវបន្តធ្វើចត្តាឡីស័ករយៈពេល ៧ថ្ងៃ និងថ្ងៃទី៧ត្រូវធ្វើតេស្តម្ដងទៀត បើលទ្ធផលនៅអវិជ្ជមានទៀត ទើបអនុញ្ញាតឱ្យទៅរោងចក្រធ្វើការ។ ក្នុងករណីមានវិជ្ជមានកូវីដ-១៩ ត្រូវបញ្ជូនទៅកន្លែងព្យាបាលហើយរាល់ការចំណាយទៅលើការព្យាបាលជាបន្ទុករបស់និយោជកថៃទាំងស្រុង។ លោក អន ប៊ុនហាក់ បានបញ្ជាក់ថា ការលើកលែងការធ្វើចត្តាឡីស័កនេះ ជួយកាត់បន្ថយការចំណាយដ៏ធំរបស់និយោជកថៃក្នុងការទទួលយកពលករ ព្រោះថាក្នុងចំណោមពលករម្នាក់ថៅកែថៃត្រូវចំណាយប្រមាណ១ម៉ឺនបាតប្រហាក់ប្រហែល ៣០០ ដុល្លារអាមេរិក និងជួយជំរុញឱ្យនិយោជកថៃបង្កើនចំនួនក្នុងការទទួលយកពលករខ្មែរដោយរំពឹងថានឹងអាចបញ្ជូនទៅក្នុង១ខែពី១ម៉ឺននាក់ទៅ១៥ ០០០នាក់ដូចមុនកំលុងពេលផ្ទុះជំងឺកូវីដ១៩។

យោងតាមរបាយការណ៍របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈបានឱ្យដឹងថា បច្ចុប្បន្ននេះកម្ពុជាមានពលករកំពុងធ្វើការងារនៅប្រទេសថៃមានចំនួន១.២២០.១៩៧នាក់ដោយធ្វើលើផ្នែកសំណង់កសិកម្ម នេសាទ និងរោងចក្រចំណីអាហារ៕ អត្ថបទ៖ សំអឿន

## ពលរដ្ឋថៃ ធ្វើការនៅកាស៊ីណូខ្មែរ ខឹងសម្បារប្រកាសនាំគ្នាធ្វើបាតុកម្មនៅស្ថានទូតខ្មែរ រឿងអាជ្ញាធរយកប្រាក់ពីពួកគេគ្រប់ពេលឆ្លងដែន

https://kbn.news/ June 3, 2022

ថ្មីៗនេះមានម្ចាស់គណនីហ្វេសប៊ុកមួយដែលមានឈ្មោះថា New Lable Aran បានរិះគន់មកលើអាជ្ញាធរដែលប្រចាំការនៅច្រកព្រំដែនខ្មែរ-ថៃ ដោយគេបានអះអាងថាបានធ្វើដំណើរចូលមកក្នុងប្រទេសកម្ពុជានៅច្រកប៉ោយប៉ែត គឺត្រូវបង់ប្រាក់ចំនួន ១,០០០បាត ទៅ ២,០០០បាត និងចំណាយទៅលើសេវាផ្សេងៗជាច្រើនផ្សេងទៀត។ កាលពីថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២២ កន្លងទៅនេះមានម្ចាស់គណនីអាខោនហ្វេសប៊ុកមួយដែលមានឈ្មោះថា New Lable Aran ជាជនជាតិថៃ បានធ្វើការផុសរិះគន់កើតទុក្ខមិនសុខចិត្ត ព្រោះតែគាត់ពេល ធ្វើដំណើរឆ្លងកាត់ព្រំដែននៅច្រកប៉ោយប៉ែតដើម្បីឆ្លងចូលមកក្នុងប្រទេសកម្ពុជា ដោយមានលិខិតឆ្លងដែនត្រឹមត្រូវ ប៉ុន្តែរឿងដ៏ហួសចិត្ត និងធ្វើឱ្យគាត់មានការមិនសប្បាយចិត្តព្រោះតែការឆ្លងដែនរបស់គាត់គេតម្រូវឱ្យបង់ប្រាក់ពីចន្លោះ ១,០០០បាត ទៅ ២,០០០បាត ព្រមទាំងបង់សេវាប្រចាំថ្ងៃចំនួន១០០បាត បង់ថ្លៃកាតលឿង ២០បាត និងបង់ថ្លៃកាតស ២០បាត ដោយខាងច្រកព្រំដែនប៉ោយប៉ែតបានអះអាងថាគាត់ប្រើប្រាស់លិខិតឆ្លងដែនថ្មី មិនធ្លាប់មានជាប់ត្រាចេញចូល ដូច្នេះត្រូវតែបង់ប្រាក់ ។ ទាក់ទងនិងករណីនេះបានធ្វើឱ្យគាត់ខឹងជាខ្លាំង ព្រមទាំងបានបញ្ជាក់ថាគាត់ជាជនជាតិថៃ ហើយត្រូវចូលមកធ្វើការ កាស៊ីណូក្នុងប្រទេសកម្ពុជា ជាមួយនឹងមិត្តភ័ក្តរួមការងារជាច្រើនផ្សេងទៀត ហើយពួកគេបាននិយាយថាប្រជាជនថៃមិនអាចទ្រាំទ្របានទេ ដូច្នេះនៅក្នុងថ្ងៃទី ៨ ខែមិថុនា ឆ្នាំ២០២២ ខាងមុខនេះពួកគេនឹងនាំគ្នាទៅធ្វើការតវ៉ានៅមុខស្ថានទូតកម្ពុជា ដែលស្ថិតនៅក្នុងប្រទេសថៃ នៅផ្លូវបំបែក Khok Sabang នៅវេលាម៉ោង ១០ព្រឹក។ ក្រោយពីធ្វើការបង្ហោះនូវសារទាំងអស់នេះហើយក៏បានធ្វើឱ្យប្រជាជនថៃជាច្រើននាក់បានចូលទៅខមមិនរិះគន់យ៉ាងចាស់ដៃ មកលើអាជ្ញាធរប្រចាំការនៅច្រកព្រំដែនប៉ោយប៉ែតយ៉ាងព្រោងព្រាត។ យ៉ាងណាមិញទាក់ទងនឹងករណីខាងលើយើងក៏មិនទាន់ដឹងច្បាស់ពីរឿងរ៉ាវស៊ីជម្រៅជាងនេះយ៉ាងណានោះដែរ៕

## កិច្ចព្រមព្រៀងការងារអនុញ្ញាតឱ្យពលករចំណាកស្រុកខ្មែរជាង៥២,០០០នាក់ចូលប្រទេសថៃដោយមិនបាច់ធ្វើចត្តាឡីស័ក

https://www.khmertimeskh.com/ June 5, 2022

ក្រសួងការងារបានឱ្យដឹងថា ពលករចំណាកស្រុកជាង ១៦ម៉ឺននាក់ រួមទាំង ៥២,៤២៨នាក់ មកពីប្រទេសកម្ពុជា នឹងត្រូវនាំចូលទៅក្នុងប្រទេសថៃ ដោយមិនតម្រូវឱ្យមានការធ្វើចត្តាឡីស័ក តាមរយៈអនុស្សរណៈនៃការយោគយល់គ្នា (MoU) ដែលបានចុះហត្ថលេខាថ្មី ក្នុងគោលបំណងទប់ស្កាត់អ្នកឆ្លងដែនខុសច្បាប់ដែលកំពុងស្វែងរកការងារធ្វើ ។ គិតត្រឹមថ្ងៃពុធនេះ ការធ្វើចត្តាឡីស័កត្រូវបានលើកលែងសម្រាប់ពលករចំណាកស្រុកដែលចូលមកក្នុងប្រទេសតាមរយៈ MoU ដែលបានចុះហត្ថលេខាជាមួយប្រទេសកម្ពុជា មីយ៉ាន់ម៉ា និងឡាវ ប្រសិនបើពួកគេត្រូវបានចាក់វ៉ាក់សាំងពីរដូស និងធ្វើតេស្តអវិជ្ជមានកូវីដ-១៩។ ជាចំនួនសរុប និយោជកបានដាក់ពាក្យសុំនាំចូលពលករចំណាកស្រុកចំនួន ២៣៦,០១២ នាក់ ពីប្រទេសជិតខាងទាំងបី។ ក្នុងនោះមាន ១៦៥,៣៧៦នាក់មកពីមីយ៉ាន់ម៉ា ៥២,៤២៨នាក់មកពីកម្ពុជានិង ១៨,២០៨នាក់មកពីប្រទេសឡាវ។

រដ្ឋមន្ត្រីក្រសួងការងារ លោក Suchart Chomklin បាននិយាយថា ការលើកលែងការធ្វើចត្តាឡីស័កនៃមេរោគកូវីដ-១៩ សម្រាប់អ្នកស្វែងរកការងារធ្វើចំណាកស្រុកដែលត្រូវបានចាក់វ៉ាក់សាំងពេញលេញបានដំណើរការស្របគ្នាជាមួយនឹងការបើកព្រំដែនឡើងវិញ ដែលបញ្ជាដោយមជ្ឈមណ្ឌលសម្រាប់ការគ្រប់គ្រងស្ថានភាពកូវីដ-១៩ (CCSA) ដែលដឹកនាំដោយនាយករដ្ឋមន្ត្រីប្រាយុទ្ធ ចាន់អូចា។ ការលើកលែងការធ្វើចត្តាឡីស័កនឹងជួយសម្រួលការខ្វះខាតនៅក្នុងទីផ្សារការងារដែលត្រូវបានចុះកិច្ចសន្យាដោយសារតែការរាតត្បាតនៃមេរោគឆ្លង ប៉ុន្តែកំពុងវិលត្រឡប់មកវិញនៅពេលដែលអាជីវកម្មចាប់ផ្តើមដំណើរការជាបណ្តើរៗ។

លោក Suchart បាននិយាយថា ការលើកលែងនេះក៏អនុវត្តចំពោះពលករចំណាកស្រុកដែលឆ្លងដែនជារៀងរាល់ថ្ងៃ ហើយត្រឡប់ទៅប្រទេសរបស់ពួកគេវិញនៅពេលល្ងាច ក៏ដូចជាកម្មករតាមរដូវផងដែរ។ ក្រៅពីទទួលបានការចាក់វ៉ាក់សាំងពេញលេញ កម្មករត្រូវតែទិញធានារ៉ាប់រងសុខភាព។ ពួកគេក៏ជាកម្មវត្ថុនៃការត្រួតពិនិត្យសុខភាព ហើយត្រូវឆ្លងកាត់ការធ្វើតេស្តអង់ទីហ្សែនកូវីដ ATK ។ ប្រសិនបើពួកគេត្រូវបានផ្តល់វិក័យប័ត្រសុខភាពស្អាត ពួកគេនឹងត្រូវបានចេញប័ណ្ណការងារ ហើយនិយោជកអាចនាំពួកគេទៅធ្វើការនៅគ្រឹះស្ថានរបស់ពួកគេ។ ទោះយ៉ាងណាក៏ដោយ ប្រសិនបើរកឃើញជំងឺកូវីដ-១៩ ពលករនឹងត្រូវដាក់ឱ្យធ្វើចត្តាឡីស័ក។ ការចំណាយដែលទាក់ទងនឹងការធ្វើចត្តាឡីស័ក ឬការព្យាបាលនឹងត្រូវបានយកមកវិញដោយការធានារ៉ាប់រងសុខភាពដែលមានតម្លៃយ៉ាងតិច ៤,០០០ដុល្លារ (១៣២,០០០បាត) ដែលពលករបានដកចេញ។ ប្រសិនបើការចំណាយលើសពីការធានារ៉ាប់រង និយោជកត្រូវចំណាយលើចំនួនដែលនៅសេសសល់។

## ជនជាតិរ៉ូហ៊ីងយ៉ាជិត៦០នាក់ ត្រូវឈ្មួញបោះបង់ចោលនៅលើកោះមួយ

https://kohsantepheapdaily.com.kh/ ០៦ ខែ មិថុនា ឆ្នាំ ២០២២ ម៉ោង ១៥:២៤

ថៃ ៖ ប៉ូលីសថៃបានរកឃើញជនជាតិរ៉ូហ៊ីងយ៉ាចំនួន ៥៩នាក់ ដែលត្រូវបានពួកឈ្មួញបោះបង់ចោលនៅលើកោះ Koh Dong របស់ប្រទេសថៃអំឡុងការធ្វើដំណើរទៅកាន់ប្រទេសម៉ាឡេស៊ី។ នេះបើយោងតាមការបញ្ជាក់របស់ប៉ូលីសថៃកាលពីថ្ងៃអាទិត្យ ទី ៥ ខែមិថុនា កន្លងទៅនេះ ។

ឧត្តមសេនីយ៍ទោ Surachet Hakpin បាននិយាយថា ក្នុងចំណោមពួកគេ មានកុមារចំនួន ៥នាក់។ ពួកគេត្រូវបានរកឃើញនៅលើកោះកាលពីថ្ងៃសៅរ៍កន្លងទៅនេះ ស្ថិតនៅភាគខាងត្បូងខេត្ត Satun។ ជារៀងរាល់ឆ្នាំ ជនជាតិដើមភាគតិចរ៉ូហ៊ីងយ៉ាកាន់សាសនាអ៊ីស្លាមរាប់ពាន់នាក់ ដែលត្រូវបានធ្វើទុក្ខបុកម្នេញនៅក្នុងប្រទេសមីយ៉ាន់ម៉ាបានប្រថុយជីវិតពួកគេដើម្បីធ្វើដំណើរតាមសមុទ្រថៃដែលមានរយៈពេលវែងនិងថ្លៃដើម្បីទៅកាន់ប្រទេសម៉ាឡេស៊ី។ ប៉ូលីសនិយាយថា ពួកគេត្រូវបានចោទប្រកាន់ពីបទចូលទឹកដីថៃដោយខុសច្បាប់ និងប្រឈមនឹងការបណ្តេញចេញទៅកាន់ប្រទេសមីយ៉ានម៉ាវិញ បន្ទាប់ពីសំណុំរឿងនៅតុលាការ។ លោក Surachet Hakpin និយាយថា «យើងផ្តល់ជំនួយមនុស្សធម៌ដល់ពួកគេ ហើយយើងនឹងធ្វើការស៊ើបអង្កេតដើម្បីដឹងថាតើពួកគេជាជនរងគ្រោះនៃការជួញដូរមនុស្ស ឬចូលទឹកដីថៃដោយខុសច្បាប់»។

សេចក្តីប្រកាសរបស់ប៉ូលីសបញ្ជាក់ថា ជនជាតិរ៉ូហ៊ីយ៉ាទាំងនោះទំនងជាអត់ឃ្លានខ្លាំង និងមិនមានអាហារហូបរយៈពេលពី ៣ ទៅ ៥ថ្ងៃ។ ពួកគេបាននិយាយថា ទូករបស់ពួកគេស្ថិតក្នុងចំណោមទូក ៣គ្រឿងដែលមានដឹកមនុស្ស ១៧៨នាក់ ដែលបានចាកចេញពីប្រទេសមីយ៉ាន់ម៉ា និងបង់ក្លាដេស ដោយបង់ប្រាក់ប្រហែល ១.១០០ ដុល្លារសម្រាប់ថ្លៃធ្វើដំណើរ។ សេចក្តីប្រកាសរបស់ប៉ូលីសថៃបញ្ជាក់ថា ទូក២ដំបូងដែលមានដឹកមនុស្សចំនួន ១១៩នាក់ ត្រូវបានបញ្ឈប់ និងចាប់ខ្លួនដោយអាជ្ញាធរម៉ាឡេស៊ី។ ក្រោយមក នាវិកទូកទី ៣ បានសម្រេចចិត្តបោះបង់ពួកគេចោលនៅលើទូកនៅកោះ Koh Dong ដោយប្រាប់ពួកគេថា ពួកគេបានធ្វើដំណើរមកដល់ប្រទេសម៉ា

ឡេស៊ីហើយ។ សូមបញ្ជាក់ថា ការប្រទះឃើញជនជាតិរ៉ូហ៊ីយ៉ាដែលត្រូវគេបោះបង់ចោលទាំងនេះ កើតឡើង បន្ទាប់ពីសាកស.ពជនជាតិរ៉ូហ៊ីងយ៉ាងចំនួន ១៤នាក់រួមទាំងកុមារផងនោះ ត្រូវបានគេប្រទះឃើញនៅឆ្នេរខ្សាច់កាលពីខែមុន ក្រោយពេលពួកគេព្យាយាមរត់គេចចេញពីមីយ៉ាន់ម៉ា៕ (យោងតាមប្រភព៖ AFP/)

# ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២២

## រយៈពេល ១ សប្តាហ៍ ពលករខ្មែរចំនួន ៥៩ នាក់ បម្រុងលួចឆ្លងដែន ចូលប្រទេសថៃ ត្រូវបានទប់ស្កាត់

https://www.postkhmer.com/ ឡាយ សាមាន | Publication date 07 June 2022 | 16:19 ICT

**បន្ទាយមានជ័យៈ** គិតត្រឹមរយៈពេល ១ សប្តាហ៍ ដើមខែមិថុនានេះ ពលករខ្មែរជិត ៦០ នាក់ ដែលបម្រុងលួចឆ្លងដែនខុសច្បាប់ទៅប្រទេសថៃ តាមច្រកខេត្តបន្ទាយមានជ័យ ត្រូវបានសមត្ថកិច្ចទប់ស្កាត់ទាន់ពេលវេលា និងបានណែនាំឱ្យបញ្ឈប់សកម្មភាពបែបនេះដែលនឹងអាចបង្កគ្រោះថ្នាក់ផ្សេងៗ។ បន្ទាប់ពីរាជរដ្ឋាភិបាលកម្ពុជា និងថៃ ព្រមព្រៀងគ្នាបើកច្រកទ្វារព្រំដែនឡើងវិញជាបណ្តោះអាសន្ន កាលពីដើមខែឧសភា ឆ្នាំ ២០២២ មកពលករខ្លះសម្រុកធ្វើបណ្ណព្រំដែន និងឯកសារផ្សេង ដើម្បីបានទៅធ្វើការស្របច្បាប់នៅថៃ។ ទន្ទឹមនឹងនោះក៏មានពលរដ្ឋខ្មែរមួយចំនួនដែលខ្វះខាត និងមិនមានលទ្ធភាពធ្វើឯកសារផ្សេងៗ សម្រេចចិត្តលួចឆ្លងដែនខុសច្បាប់ទាំងប្រថុយប្រថាន ទោះបីអាជ្ញាធរកម្ពុជារឹតបន្តឹងនៅតាមខ្សែបន្ទាត់ព្រំដែនក៏ដោយ។

លោក សួង សៅ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨១៥ នៃខេត្តបន្ទាយមានជ័យ បានឱ្យដឹងថា កម្លាំងព្រំដែនសហការជាមួយកម្លាំងប៉ុស្តិ៍ចំបក់ និងកម្លាំងយោធាផ្នែកសឹករងក្រុងប៉ោយប៉ែត បានចេញប្រតិបត្តិការក្នុងការទប់ស្កាត់ពលករបាន ៥៩ នាក់ ក្នុងនោះស្រី ២១ នាក់ នាដើមខែមិថុនានេះ ដែលបម្រុងលួចឆ្លងដែនខុសច្បាប់ទៅប្រទេសថៃ។ ប្រតិបត្តិការនោះធ្វើឡើងនៅស្រុកម៉ាឡៃ ដោយនៅថ្ងៃទី ៦ មិថុនា ទប់ស្កាត់បាន ១៥ នាក់ និងថ្ងៃទី ៤ មិថុនា ទប់ស្កាត់បានរហូតដល់ ៤៤ នាក់។ លោកបញ្ជាក់ថា៖ «ក្នុងចំណោមពលករទាំងនោះមកពីខេត្តបន្ទាយមានជ័យ សៀមរាប បាត់ដំបង កំពត ព្រៃវែង ឧត្តមានជ័យ កំពង់ស្ពឺ និងត្បូងឃ្មុំជាដើម ហើយពលករទាំងអស់បន្ទាប់ពីធ្វើការសួរនាំ អប់រំ និងធ្វើការសន្យារួច គឺបានអនុញ្ញាតឱ្យវិលត្រឡប់ទៅលំនៅឋានវិញរៀងៗខ្លួន»។ ជាមួយគ្នានេះលោកបានណែនាំដល់កងកម្លាំង ត្រូវយកចិត្តទុកដាក់ការពារ សណ្តាប់ធ្នាប់តាមខ្សែបន្ទាត់ព្រំដែន ជាពិសេសពង្រឹងទប់ស្កាត់ការលួចឆ្លងដែនខុសច្បាប់។

នាយប៉ុស្តិ៍នគរបាលការពារព្រំដែនគោកក្បាលទំនប់ លោក រឿម ប៊ុនរិទ្ធ ឱ្យដឹងថា ពលករនៅបន្តលួចឆ្លងដែនខុសច្បាប់ជាបន្តបន្ទាប់ ទោះបីសមត្ថកិច្ចធ្លាប់ផ្សព្វផ្សាយ អប់រំ និងបានដាក់កម្លាំងការពារនៅព្រំដែនយ៉ាងណាក៏ដោយ។ លោកបញ្ជាក់ថា៖ «សមត្ថកិច្ចយើងខំប្រឹងប្រែងទាំងយប់ ថ្ងៃ ដើម្បីទប់ស្កាត់ និងបានបានណែនាំ អប់រំគាត់ឱ្យទៅតាមច្រកព្រំដែនស្របច្បាប់ ព្រោះទៅច្រកខុសច្បាប់ វាប្រឈមគ្រោះថ្នាក់ច្រើន ដូចជាការគេចពីសមត្ថកិច្ច ឬគ្រោះថ្នាក់ផ្សេង»។ លោកឱ្យដឹងថា តាមអ្វីដែលមត្ថកិច្ចសួរនាំកន្លងមក ពលករទាំងនោះភាគច្រើនថា មិនមានលិខិតឆ្លងដែន និងខ្វះថវិកា ទើបពួកគេសម្រេចចិត្តឆ្លងដែនខុសច្បាប់ទាំងប្រថុយប្រថាន។ លោកនិយាយថា៖ «ដោយសារគាត់អត់មានលិខិតឆ្លងដែន អ៊ីចឹងដោយយោងតាមជីវភាពខ្វះខាតផង និងខ្លះជំពាក់លុយធនាគារ ទើបពលរដ្ឋនៅតែលួចឆ្លងដែន ទោះបីយើងខំទប់ស្កាត់ អប់រំយ៉ាងណា ក៏គាត់នៅតែឆ្លៀតពេលលួចឆ្លងដែន ហើយគាត់ជាពលរដ្ឋយើង។ អ៊ីចឹង គ្រាន់តែអប់រំណែនាំគាត់ឱ្យទៅតាមផ្លូវត្រូវ យើងមិនធ្វើទារុណកម្ម ដាក់ពិន័យទេ»។

អភិបាលស្រុកកំរៀង នៃខេត្តបាត់ដំបង លោក គៀន សត្យា បានឱ្យដឹងថា ដោយសារច្រកអន្តរជាតិដូងខេត្តបាត់ដំបង ជាប់ខេត្តច័ន្ទបុរី ត្រូវបានបើកឡើងវិញជាបណ្តោះអាសន្ន ទើបពលករសម្រុកទៅធ្វើបណ្ណស្របច្បាប់

និងកាត់បន្ថយការឆ្លងដែនខុសច្បាប់។ លោកថ្លែងថា៖ «យើងបានផ្សព្វផ្សាយ ចាក់មេក្រូនៅតាមភូមិ-ឃុំ ជាហូរហែ ណែនាំកុំឱ្យឆ្លងដែនខុសច្បាប់ ហើយឥឡូវនេះពលករសម្រុកមកធ្វើបណ្ណឆ្លងដែន។ គិតពីដើមខែមិថុនាមក អត់មានពលករឆ្លងដែនខុសច្បាប់ទេ»៕

## នៅព្រឹកថ្ងៃអង្គារ អាជ្ញាធរស្រុកសំពៅលូន បន្តទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ពីប្រទេសថៃ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ

https://gdlf-kh.com/ 2022/06/07/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅវេលាម៉ោង ០៦ និង០០នាទី នាថ្ងៃអង្គារ ៨កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពាព្រំដែនគោក លេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍គីឡូ១៣ ចំនួន០៣នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក ម៉ឹង-ម៉េត (នាយប៉ុស្តិ៍) សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូនចំនួន០៣នាក់ ដឹកនាំដោយលោកនាយចំណង់ ជា យ៉ាន (មេបញ្ជាការកងអនុសេនាតូច) កម្លាំងយោធាវរសេនាតូច៥៣៣ ចំនួន០៣នាក់ ដឹកនាំ ដោយលោកអនុសេនីយ៍ឯក ពៅ-ចំរើន (មេបញ្ជាការរងកងអនុសេនាធំ) បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន១លើក សរុបចំនួន២២នាក់ ស្រី១១នាក់ ក្មេងប្រុសម្នាក់។ ក្រោយពីទទួលបាន កម្លាំងយើងបានធ្វើកត់ឈ្មោះ ចុះកំណត់ហេតុប្រចាំថ្ងៃ អប់រំណែនាំ រួចបានប្រគល់បងប្អូនទាំងអស់ឱ្យទៅក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូន ធ្វើការពិនិត្យ និងស្ទែនប័ណ្ណចាក់វ៉ាក់សាំងចេញត្រឹមត្រូវទាំងអស់ បន្ទាប់មកក្រុមគ្រូពេទ្យបានអនុញ្ញាតឲ្យបងប្អូនត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួន។

# ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២២

## ពលករខ្មែរ៣នាក់ ត្រូវឃាត់ខ្លួនខណៈបម្រុងលួចឆ្លងដែនទៅថៃ ដោយខុសច្បាប់តាមរយៈមេខ្យល់

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ០៨ ខែ មិថុនា ឆ្នាំ ២០២២ ម៉ោង ១០:៤១

បន្ទាយមានជ័យ ៖ ពលករខ្មែរប្រុសស្រី៣នាក់ ត្រូវបានឃាត់ខ្លួនតាមបន្ទាត់ព្រំដែននៅពេលបម្រុងលួចឆ្លងដែនចូលទៅរកការងារធ្វើនៅប្រទេសថៃ ដោយខុសច្បាប់តាមរយៈមេខ្យល់ដែលឃាត់ខ្លួន កាលពីវេលាម៉ោង៨ និង៣០នាទីព្រឹក ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២២នៅចំណុចអូរព្រំដែនភូមិក្បាលទំនប់ ឃុំអូរសំព័រ ស្រុកម៉ាឡៃ។

លោកវរៈសេនីយ៍ឯក សួង សៅ មេបញ្ជាការវរៈសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៥បានប្រាប់ថា ៖ ជាការណែនាំពីឯកឧត្តម នាយឧត្តមសេនីយ៍ ខេង សុម៉េត អគ្គស្នងការរងនគរបាលជាតិ និងលោកឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ ស្នងការនគរបាលខេត្តបន្ទាយមានជ័យ ហើយកម្លាំងនគរបាលការពារព្រំដែនគោកលេខ ៨១៥ បានចេញល្បាតតាមបន្ទាត់ព្រំដែនក្នុងភូមិសាស្ត្រស្រុកម៉ាឡៃ បានប្រទះឃើញពលករខ្មែរចំនួន៣នាក់ ស្រី២នាក់ ដែលបម្រុងលួចឆ្លងដែនទៅរកការងារធ្វើនៅប្រទេសថៃដោយខុសច្បាប់ ។ លោកបានបញ្ជាក់ថា ៖ ក្រោយ

ឃាត់ពលករខ្មែរប្រុសស្រី៣នាក់ បានបញ្ជូនមកបញ្ជាការដ្ឋានវរៈសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៥ ដើម្បីសាកសួរតាមចម្លើយសារភាព គឺពួកគាត់មានបំណងលួចឆ្លងដែនទៅរកការងារធ្វើនៅប្រទេសថៃដោយខុសច្បាប់ តាមរយៈមេខ្យល់ដែលយកម្នាក់តម្លៃ៦.០០០បាត ទទួលជូនទៅរកការងារធ្វើដល់កន្លែង ហើយនៅពេលជូនដល់អូរព្រំដែនរងចាំមេខ្យល់ថៃមកទទួលយកទៅជិះរថយន្ត ត្រូវបានកម្លាំងសមត្ថកិច្ចឃាត់ខ្លួនធ្វើណែនាំហើយធ្វើកិច្ចសន្យាអោយត្រឡប់ទៅផ្ទះវិញ ។

លោកវរៈសេនីយ៍ទោ ម៉ាន់ ធី អធិការរងនគរបាលស្រុកអូរជ្រៅ និងជាក្រុមការងារទទួលពលករខ្មែរត្រឡប់ពីថៃតាមច្រកអូរបីជាន់បានប្រាប់ថា ៖ នៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២២ ក្រុមការងារបានទទួលពលករខ្មែរត្រឡប់ពីប្រទេសថៃតាមច្រកអូរបីជាន់ស្រុកអូរជ្រៅ រយៈពេល១ថ្ងៃមានចំនួន៨៧នាក់ ស្រី៤៩នាក់ កុមារ៣នាក់ ហើយពលករខ្មែរដែលមានឯកសារចាក់វ៉ាក់សាំងការពារកូវីដ.១៩ដែលចាក់ដូសទី២និងទី៣ មានចំនួន៨៤នាក់ ស្រី៤៧នាក់ កុមារ៨នាក់ កុមារី៨នាក់ ស្រី៣នាក់ ៕

## ត្រឹម៣ខែ កម្ពុជា បញ្ជូនពលករ និងកម្មសិក្សាការី ៨៥00នាក់ ទៅធ្វើការ និងសិក្សានៅប្រទេសជប៉ុន

https://www.kampucheathmey.com/ ថ្ងៃពុធ ៨ មិថុនា ២០២២ដោយ Sokhom Khon

រយៈពេល៣ខែ ចាប់ពីខែមីនា ដល់ខែឧសភា ដើមឆ្នាំ២០២២នេះ កម្ពុជា បានបញ្ជូនពលករជំនាញ និងកម្មសិក្សាការីប្រមាណ៨៥០០នាក់ ទៅធ្វើការ និងសិក្សានៅប្រទេសជប៉ុន។

លោក អន ប៊ុនហាក់ ប្រធានសមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជាបានឱ្យដឹងនៅព្រឹកថ្ងៃទី០៨ ខែមិថុនានេះថា កម្ពុជាទើបចាប់ផ្តើមបញ្ជូនពលករជំនាញ និងកម្មសិក្សារីទៅធ្វើការនៅប្រទេសជប៉ុននៅខែមីនា ឆ្នាំ២០២២នេះទេដោយសារប្រទេសជប៉ុនបានបិទព្រំដែនដែលបណ្តាលមកពីការឆ្លងរាតត្បាតជំងឺកូវីដ-១៩។ លោក អន ប៊ុនហាក់ បានបន្តថា រយៈពេល៣ខែនេះ យើងបានបញ្ជូនពលករ និងកម្មសិក្សាការីទៅប្រទេសជប៉ុនបានប្រមាណ៨៥០០នាក់ ហើយចាប់ពីពេលនេះទៅ យើងអាចបញ្ជូនពលករ និងកម្មសិក្សាការីទៅជប៉ុនបានទៀងទាត់ឡើងវិញហើយ ដោយក្នុង១ខែៗ អាចបញ្ជូនពី ៣០០០ ទៅ៤០០០នាក់។ លោក អន ប៊ុនហាក់ បានបន្ថែមទៀតថា ក្នុងចំណោមពលករខ្មែរទៅធ្វើការនៅជប៉ុនភាគច្រើនជាកម្មសិក្សាការី។ ចំណែកពលករជំនាញមានមិនច្រើនទេ ដោយពួកគេទៅធ្វើការលើផ្នែកវេចខ្ចប់ សំណង់ ចំណីអាហារ សវាកម្ម សណ្ឋាគារ ភោជនីដ្ឋាន កសិកម្មដាំដុះ និងចិញ្ចឹមសត្វ។

ប្រធានភ្នាក់ងារហត្ថពលកម្មកម្ពុជា រូបនេះបានបន្ថែមថា ចំពោះនីតីវិធី និងបែបបទសុខាភិបាលក្នុងការបញ្ជូនពលករខ្មែរទៅប្រទេសជប៉ុន មិនតម្រូវឱ្យធ្វើចត្តាឡីស័កទៀតទេ ដោយសារប្រទេសកម្ពុជា ជាប្រទេសមួយដែលស្ថិតនៅក្នុងប្រទេសដែលមានហានិភ័យទាបកម្រិតលេខ១ ពោលគឺប្រទេសដែលមានឆ្លងជំងឺកូវីដតិចតួច ឬមិនមានឆ្លង ហើយក៏មិនកំណត់ប្រភេទវ៉ាក់សាំងដែរទោះពលករចាក់វ៉ាក់សាំងស៊ីណូវ៉ាក់ ស៊ីណូហ្វាម អាស្ត្រាហ្សេនេកា ភីហ្វាយហ្ស៊ី ក៏អាចចូលទៅក្នុងប្រទេសជប៉ុនបានដែរ។ លោក អន ប៊ុនហាក់ បានបញ្ជាល់ថា ឥឡូវនេះអាចថាមានប្រមាណ៩០ភាគទៅរកប្រក្រតីភាពធម្មតាឡើងវិញដូចមុនសម័យកូវីដ១៩ គ្រាន់តែជប៉ុនទាមទារឱ្យពលករធ្វើតេស្តរកជំងឺកូវីដ-១៩រយៈពេល៧២ម៉ោង តាមម៉ាស៊ីន PCR ឬតេស្តរហ័សដែលធ្វើដោយគ្រូពេទ្យជំនាញដើម្បីបញ្ជាក់វិញ្ញាបនបត្រថា មិនមានឆ្លងជំងឺកូវីដ-១៩។

គួរបញ្ជាក់ថា បច្ចុប្បន្ននេះមានពលករខ្មែរប្រមាណជាង១លាន២សែននាក់ធ្វើការនៅក្រៅប្រទេស ក្នុងនោះនៅថៃមានច្រើនជាងគេរហូតដល់ទៅ១,២២លាននាក់ នៅកូរ៉េខាងត្បូងមានជាង ៤៥,០០០នាក់ នៅម៉ាឡេស៊ីមាន

២៣,០២៧នាក់ នៅជប៉ុនមាន១១,៤៥៣នាក់ នៅសិង្ហបុរីមាន៨២១ នាក់ នៅចិនហុងកុង មាន២០២នាក់ និងអារ៉ាប៊ីសាអូឌីត៤៣នាក់៕ អត្ថបទ៖ សំអឿន

## ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២២

### មន្ត្រីជាន់ខ្ពស់ក្រសួងការងារ៖ រាជរដ្ឋាភិបាលកម្ពុជា ចាត់ទុកការលុបបំបាត់ពលកម្មកុមារជាការងារអាទិភាព

https://cen.com.kh/ Posted ByPen Srey NeatJune 11, 2022

ភ្នំពេញ ៖ រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជាបានចាត់ទុកថា ការលុបបំបាត់ពលកម្មកុមារជាការងារអាទិភាព ដោយនៅប្រទេសកម្ពុជា ការដកហូតនិងទប់ស្កាត់ ពីពលកម្មកុមារ និងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ដោយផ្តល់ឱកាសដល់ពួកគេទទួលបានការអប់រំ បំណិនជីវិត និងបណ្តុះបណ្តាលជំនាញ ដើម្បីលើកកម្ពស់ជីវភាពឱ្យកាន់តែប្រសើរឡើង។

នេះជាការលើកឡើងរបស់ លោកជំទាវ ស៊ើង សរសុចិត្តា រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងឱកាសខួបលើកទី៧៣ ទិវាកុមារអន្តរជាតិ ១មិថុនា ខួបលើកទី២១ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២មិថុនា និងទិវាកុមារកម្ពុជា ឆ្នាំ២០២២ ក្រោមប្រធានបទសកលស្តីពី "កិច្ចគាំពារសង្គមជាសកល ដើម្បីបញ្ចប់ពលកម្មកុមារ" រៀបចំធ្វើឡើងនៅទីស្តីការក្រសួងការងារ នាព្រឹកថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២២។ លោកជំទាវរដ្ឋលេខាធិការ បញ្ជាក់បន្ថែមថា បើទោះបីជាមានការរីករាលដាលជំងឺកូវីត-១៩ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅតែបន្តផ្តល់កិច្ចអន្តរាគមន៍ស្នូលដល់កុមារ រងគ្រោះ និងងាយរងគ្រោះដោយសារពលកម្មកុមារតាមបណ្តាខេត្តគោលដៅ ម្យ៉ាងវិញទៀតរាជរដ្ឋាភិបាល បានដាក់ឱ្យអនុវត្តនូវកម្មវិធី ឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកូនអាយុក្រោម២ឆ្នាំក្នុងគ្រួសារក្រីក្រ សរុបជាង៦០ម៉ឺនគ្រួសារ ដើម្បីសំរាលបន្ទុក លើកកម្ពស់ជីវភាព និងអាហារូបត្ថម្ភដល់ស្ត្រី និងកុមារ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ កំពុងបន្តលុបបំបាត់ពលកម្មកុមារ តាមផែនការសកម្មភាពជាតិស្តីពីការកាត់បន្ថយពលកម្មកុមារ និងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ (២០១៦-២០២៥) ដែលស្របទៅនឹងគោលដៅអភិវឌ្ឍន៍សកលប្រកបដោយចីរភាព (២០១៥-២០៣០)។ បច្ចុប្បន្ននេះ អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ(គ.ជ.ព.) និងនាយកដ្ឋានការងារកុមារ ដែលជាសេនាធិការរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏បានផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើសុខភាព សុវត្ថិភាពការងារសម្រាប់កម្មករនិយោជិតវ័យក្មេង និងទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារនៅតាមរោងចក្រ សហគ្រាស ដើម្បីសមធម៌ កំណើនសេដ្ឋកិច្ច និងការងារសមរម្យសម្រាប់យុវជន លើសពីនេះ ក្រសួងបានរៀបចំលិខិតបទដ្ឋានគតិយុត្តិមួយចំនួន ដើម្បីការពារឧត្តមប្រយោជន៍ របស់កុមារពីគ្រោះថ្នាក់ការងារផ្សេងៗ។

លោកជំទាវ ស៊ើង សរសុចិត្តា មានប្រសាសន៍បន្តថា រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំ ប្រកបដោយគតិបណ្ឌិតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំង ក្នុងការដោះស្រាយនូវបញ្ហាប្រឈមនានាចំពោះកុមារ តាមរយៈការដាក់ចេញនូវគោលនយោបាយ ផែនការសកម្មភាពជាតិពាក់ព័ន្ធនឹងកុមារ និងការបង្កើតយន្តការជាច្រើននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីសម្របសម្រួល ពិនិត្យតាមដានវឌ្ឍនភាព និងបញ្ហាប្រឈមស្តីពីស្ថានភាពកុមារនៅកម្ពុជា ឱ្យកាន់តែមានប្រសិទ្ធភាព។ ទន្ទឹមនឹងនេះ ដើម្បីសម្រេចឱ្យបាននូវគោលដៅ អភិវឌ្ឍន៍សកលប្រកបដោយចីរភាព

(២០១៥-២០៣០) ដែលចែងអំពីការបញ្ចប់ពលកម្មកុមារ នៅឆ្នាំ២០២៥ រាជរដ្ឋាភិបាលកម្ពុជាមានវិធានការនិងប្ដេជ្ញាចិត្តដូចតទៅ៖

•បន្តពង្រឹងយន្តការអនុវត្តច្បាប់និងអធិការកិច្ចការងារ និងសហការជាមួយអង្គការនិយោជិត និយោជកដើម្បីដោះស្រាយករណីវិវាទពលកម្មកុមារ និងសុវត្ថិភាពការងារឱ្យបានទាន់ពេលវេលា ជាពិសេសជំរុញនិយោជកគោរពច្បាប់ និងបទដ្ឋានគតិយុត្តនានា និងការដាក់ពិន័យកម្រិតធ្ងន់សម្រាប់រោងចក្រសហគ្រាស ដែលប្រើប្រាស់ពលកម្មកុមារ។

•ពង្រីកកិច្ចសហការអន្តរវិស័យ និងស្វែងរកដំណោះស្រាយសមស្រប ចំពោះបញ្ហាពលកម្មកុមារដែលមានចរិតលក្ខណៈពហុវិស័យ ដើម្បីធានាឧត្តមប្រយោជន៍របស់កុមារកម្ពុជា និងកសាងមូលធនមនុស្សស្របតាមបរិបទការងារសមរម្យ។

•ជំរុញឱ្យគ្រប់ភាគីពាក់ព័ន្ធសហការគ្នា ដើម្បីធានាសុវត្ថិភាពការងារសម្រាប់កម្មករនិយោជិតវ័យក្មេង និងអំពាវនាវសាធារណៈជន រាយការណ៍អំពីករណីពលកម្មកុមារនៅកន្លែងធ្វើការ។ ទន្ទឹមនឹងនេះ ណែនាំដល់អាណាព្យាបាល និងនិយោជកករណីរំលោភបំពានពលកម្មកុមារ ជាពិសេសកុមារបម្រើការងារក្នុងផ្ទះ គឺជាបទល្មើសព្រហ្មទណ្ឌ ដើម្បីកាត់បន្ថយការប្រើប្រាស់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ។

•ស្វែងរកការគាំទ្រ ធនធាននិងបច្ចេកទេស ដើម្បីស្រាវជ្រាវ និងចងក្រងប្រកាសពាក់ព័ន្ធនឹងពលកម្មកុមារនៃសកម្មភាពសេដ្ឋកិច្ចដែលវិវត្តន៍ថ្មីៗ និងយុទ្ធនាការឆ្ពោះទៅបញ្ចប់ពលកម្មកុមារនៅកម្រិតថ្នាក់ឃុំសង្កាត់។

គួរបញ្ជាក់ជូនដែរថា ជាមួយនឹងកិច្ចខិតខំប្រឹងប្រែង របស់រាជរដ្ឋាភិបាលកម្ពុជា បានធ្វើឱ្យប្រទេសកម្ពុជាក្លាយជាប្រទេសមួយនាំមុខក្នុងចំណោមប្រទេសទាំង៥ក្នុងពិភពលោក ដែលបានលុបបំបាត់ពលកម្មកុមារ និងមានលក្ខខណ្ឌការងារល្អប្រសើរ មានគោលនយោបាយច្បាស់លាស់ ក្នុងការប្រឆាំងនឹងពលកម្មកុមារ និងជាប្រទេសនាំមុខមធ្យម ក្នុងចំណោមប្រទេសនាំមុខទាំង១៣ នៅលើពិភពលោកក្នុងវឌ្ឍនភាពប្រឆាំងពលកម្មកុមារ៕ រក្សាសិទ្ធិដោយ ៖ សុទ្ធ លី

## អាជ្ញាធរស្រុកសំពៅលូន ទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ពីប្រទេសថៃ ត្រង់ភូមិសាស្ត្រ ភូមិកូនភ្នំខាងជើង ឃុំតាស្ដា នៅចំណុចច្រកទ្វារព្រំដែនអន្តរជាតិគីឡូ១៣

https://gdlf-kh.com/ 2022/06/12/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅវេលាម៉ោង០៧និង៣០នាទី នាថ្ងៃអាទិត្យ ១៣កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំ ស្ដីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោក លេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍ព្រំដែនកូនភ្នំ ចំនួន៣នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក ខៀវ-រ៉ាត់ (នាយប៉ុស្តិ៍) សហការជាមួយកម្លាំងយោធាកងអនុសេនាធំទី១, វរសេនាតូចលេខ១ ចំនួន៣នាក់ ដឹកនាំដោយលោកអនុសេនីយ៍ត្រី ស៊ឹង-ស៊ិត (មេបញ្ជាការរងកងអនុសេនាធំ), កម្លាំងយោធាកងអនុសេនាធំគាំទ្រ, វរសេនាតូច៥៣៣ ចំនួន៣នាក់ ដឹកនាំដោយលោកអនុសេនីយ៍ត្រី ឈឹម-សុភាព (មេបញ្ជាការកងអនុសេនាតូច) បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ចំណុចភូមិសាស្ត្រ ភូមិកូនភ្នំខាងជើង ឃុំតាស្ដា ស្រុកសំពៅលូន ខេត្តបាត់ដំបង

ចំនួន៩នាក់ ស្រី៣នាក់ ក្មេង៤នាក់ ក្មេងស្រី២នាក់។ ក្រោយពីទទួលបាន កម្លាំងយើងបានធ្វើការសាកសួរ កត់ឈ្មោះ ចុះកំណត់ហេតុប្រចាំថ្ងៃ និងអប់រំណែនាំ រួចកម្លាំងយើងបានប្រគល់ពួកគាត់អោយទៅក្រុមគ្រូពេទ្យដែលប្រចាំការនៅចំណុចច្រកទ្វារព្រំដែនអន្តរជាតិគីឡូ១៣។

## ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២

### សម្តេចតេជោ ហ៊ុន សែន ផ្តល់អនុសាសន៍ចំនួន៣ ឆ្ពោះទៅការបញ្ចប់អំពើហិង្សាលើកុមារ

http://freshnewsasia.com/ 2022-06-14 08:39pm

**(ភ្នំពេញ)៖** សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា បានផ្តល់នូវអនុសាសន៍ចំនួន៣ ទៅកាន់ដៃគូពាក់ព័ន្ធ ដើម្បីឈានឆ្ពោះទៅរកការបញ្ចប់អំពើហិង្សា។ **អនុសាសន៍នេះត្រូវបានធ្វើឡើងតាមរយៈសុន្ទរកថាក្នុងកិច្ចប្រជុំកំពូលអ្នកដឹកនាំស្តីពីដំណោះស្រាយ ដើម្បីបញ្ចប់អំពើហិង្សាលើកុមារ។ អនុសាសន៍ទាំង៣នោះរួមមាន៖**

**ទី១៖** លើកកម្ពស់ស្មារតីរួបរួមគ្នា និង ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការដែលមានស្រាប់ ទាំងទ្វេភាគី និងពហុភាគី ដើម្បីលើកស្ទួយសុខុមាលកុមារ និង កិច្ចការពារកុមារ, ជាពិសេសពង្រឹងយន្តការសម្របសម្រួលក្នុងចំណោមតួអង្គពាក់ព័ន្ធទាំងអស់ សំដៅចែករំលែកទិន្នន័យ និង ព័ត៌មានសំខាន់ៗ ដើម្បីចាត់វិធានការទាន់ពេល និងតឹងរ៉ឹងដាច់ខាត ចំពោះសកម្មភាពហិង្សាគ្រប់ទម្រង់លើកុមារ។

**ទី២៖** ជំរុញការប្តេជ្ញាចិត្តជាសាកល តាមរយៈការកៀរគរធនធាន ទាំងហិរញ្ញវត្ថុ និង មិនមែនហិរញ្ញវត្ថុ ដើម្បីគាំទ្រ និងធានាចីរភាពនៃចលនាបញ្ចប់អំពើហិង្សាលើកុមារ ទាំងក្នុងក្របខណ្ឌអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិ ក៏ដូចជាតំបន់ដទៃទៀត។

**ទី៣៖** ពន្លឿនវឌ្ឍនភាពឆ្ពោះទៅរកការសម្រេចគោលដៅនានា របស់ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ជាពិសេស ចំណុចដៅ ១៦.២៖ ការបញ្ចប់រាល់ទម្រង់ទាំងអស់នៃអំពើហិង្សាលើកុមារនៅត្រឹមឆ្នាំ២០៣០។

នៅក្នុងសុន្ទរកថានេះ សម្តេចតេជោ ហ៊ុន សែន បានគូសរំលេចនូវកិច្ចប្រឹងប្រែងមួយចំនួនរបស់កម្ពុជា ក្នុងការលុបបំបាត់អំពើហិង្សាលើកុមារផងដែរ។ សម្តេចតេជោ បានបញ្ជាក់ថា រាជរដ្ឋាភិបាលកម្ពុជាតែងតែយកចិត្តទុកដាក់ខ្ពស់លើការទប់ស្កាត់រាល់សកម្មភាពហិង្សាលើកុមារ និង លើកកម្ពស់កិច្ចការពារកុមារ។ ជាក់ស្តែងកម្ពុជាបានរៀបចំ និងដាក់ឱ្យអនុវត្តនូវគោលនយោបាយ និង ផែនការជាបន្តបន្ទាប់ ដូចជា ផែនការសកម្មភាព ដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ ២០១៧-២០២១, ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ ២០១៦-២០២៥ និងគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារ ឆ្នាំ ២០១៩-២០២៩ ជាដើម ដើម្បីឈានទៅសម្រេចឱ្យបាននូវការបញ្ចប់អំពើហិង្សាលើកុមារ។ បន្ថែមលើនេះ នៅឆ្នាំ២០១៩ កម្ពុជាបានក្លាយជាប្រទេសសមាជិក នៃភាពជាដៃគូសាកល ដើម្បីបញ្ចប់អំពើហិង្សាលើកុមារ ដោយផ្តល់អាទិភាពលើការពង្រឹងការអនុវត្តគោលនយោបាយថែទាំជំនួសចំពោះកុមារ តាមរយៈការលើកកម្ពស់ការថែទាំតាមគ្រួសារ ជំនួសឱ្យការថែទាំនៅកន្លែងថែទាំកុមារជាដើម។

សម្តេចតេជោ បានលើកឡើងទៀតថា នៅឆ្នាំ២០២១ ផ្អែកតាមការវាយតម្លៃលើ ផែនការសកម្មភាពដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារឆ្នាំ ២០១៧-២០២១, ប្រទេសកម្ពុជា បាននិងកំពុងស្ថិតនៅលើមាគ៌ាដ៏ត្រឹមត្រូវក្នុងការទប់ស្កាត់នឹងអំពើហិង្សាលើកុមារ។ ជាទិសដៅទៅមុខ កម្ពុជានឹងបន្តកិច្ចខិតខំប្រឹងប្រែងឱ្យកាន់តែសកម្មក្នុងការធានាថាកុមារមានសុវត្ថិភាពនៅគ្រប់ទីកន្លែង ដូចជា នៅផ្ទះ សាលារៀន និងក្នុងសហគមន៍។ ជាងនេះទៅទៀត រាជរដ្ឋាភិបាលប្តេជ្ញាយ៉ាងមុតមាំចំពោះការធានាឱ្យបានថាកុមារទាំងអស់នឹងរស់នៅក្នុងបរិយា

កាសមួយប្រកប ដោយភាពអំណោយផលដល់ការលូតលាស់ ព្រមទាំងទទួលបានការចិញ្ចឹមបីបាច់ និង កិច្ចការពារនានា សំដៅបញ្ចប់ឱ្យបានអំពើហិង្សាលើកុមារក្នុងគ្រប់ទម្រង់ និង សម្រេចឱ្យបាននូវការប្តេជ្ញារបស់កម្ពុជា ក្នុងក្របខណ្ឌតំបន់ និង សកល តាមរយៈការអនុវត្តនូវផែនការ និងគោលនយោបាយជាតិនានា ដែលបានដាក់ចេញ។ សម្តេចតេជោ ហ៊ុន សែន ក៏បានលើកឡើងដែរថា ការឈានទៅបញ្ចប់អំពើហិង្សាលើកុមារ ក៏តម្រូវឱ្យមានកិច្ចសហការជាសាកល ជាពិសេសក្នុងបរិបទនៃការបន្តរីករាលដាលនៃជំងឺកូវីដ-១៩ ដែលបានបន្ទច់បង្អាក់នូវវឌ្ឍនភាពនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) ទាក់ទងទៅនឹងការបញ្ចប់អំពើហិង្សាលើកុមារ៕

## ពលករខ្មែរជួបទុក្ខលំបាកខ្លាំងក្រោយពីភ្លើងឆេះរោងចក្រនៅប្រទេសថៃ

https://www.rfa.org/khmer/ ដោយ សន ចាន់រដ្ឋា2022.06.15

ពលករខ្មែរជាច្រើននាក់ធ្វើការនៅខេត្តរះយ៉ង(Rak Yorng)ប្រទេសថៃ ជួបទុកលំបាកក្នុងជីវភាពប្រចាំថ្ងៃ គ្មានការងារធ្វើ និងគ្មានប្រាក់ចំណាយនោះទេ បន្ទាប់ពីឆេះរោងចក្រគ្រឿងសង្ហារិមនៅប្រទេសថៃ បណ្តាលឱ្យពលករមួយចំនួនត្រូវភ្លើងឆេះលិខិតឆ្លងដែនខូចអស់។ ពលករខ្មែរច្រើននាក់ត្អូញត្អែរពីទុកលំបាក ក្រោយភ្លើងបានឆាបឆេះរោងចក្រពួកគាត់ធ្វើការ ដែលមានពលករខ្មែរធ្វើការប្រមាណ ៥០០នាក់ ។ រោងចក្រផលិតគ្រឿងសង្ហារិមដែលភ្លើងឆេះនេះ ស្ថិតនៅ ខេត្តរះយ៉ង(Rak Yorng) ។ ពលករខ្លះខូចខាត សម្ភារៈមួយចំនួន និងខ្លះត្រូវ ផ្អាកការងារជាបណ្តោះអាសន្ន ក្នុងនោះក៏មានពលករខ្មែរចំនួន១០ នាក់ ត្រូវបានភ្លើងឆេះលិខិតឆ្លងដែន ឬប៉ាស្ព័រ(Passport)។

ពលករខ្មែរធ្វើការរោងចក្រនៅខេត្តរះយ៉ង លោក ព្រួន កុសល ប្រាប់វិទ្យុអាស៊ីសេរីនៅថ្ងៃទី១៣មិថុនា ថា លោក ព្រួយបារម្ភពីជីវភាពខ្វះខាតក្នុងពេលស្នាក់នៅក្នុងប្រទេសថៃ ព្រោះបើការដោះស្រាយមានរយៈពេលយូរ ធ្វើឱ្យពួកគេមិនអាចចេញទៅរកការងារធ្វើនៅកន្លែងផ្សេងបាន ព្រោះគ្មានប្រាក់ធ្វើដំណើរ និងពិបាកក្នុងការប្តូរថៅកែ ៖ «បាទដូចថា អ្នកខ្លះគ្នាទើបមកធ្វើការបាន មួយរឺ ពីរអ៊ីចឹង មួយខែ ២ខែជាងអ៊ីចឹង គ្នាអត់ដែរបងអើយ ព្រោះអីគ្នាចងការលុយគេមក ហ្នឹងហើយគ្នាមានរឿងអ៊ីចឹងទៀតគ្នាកាន់តែលំបាក ។ លំបាកខ្លាំងហ្នឹងអ្នកខ្លះ ណាមួយការហូបចុកផង ណាមួយបង់លុយអង្គការគេនៅផ្ទះផង»។

វិទ្យុអាស៊ីសេរីមិនអាចទាក់ទងស្ថានកុងស៊ុលកម្ពុជាប្រចាំប្រទេសថៃ ដើម្បីសុំការអធិប្បាយជុំវិញរឿងនេះបានទេ ថ្ងៃទី១៣ មិថុនានេះ ដោយទូរស័ព្ទចូលគ្មានអ្នកទទួល។ ប៉ុន្តែ ទំព័រហ្វេសប៊ុក របស់ស្ថានកុងស៊ុលកម្ពុជាប្រចាំប្រទេសថៃ បានបង្ហោះរូបភាព ស្តីពីអនុព័ន្ធការងារតំណាងស្ថានទូត បានសហការជាមួយមូលនិធិលើកកម្ពស់សិទ្ធិ និងគុណភាពជីវិតពលករ (LPN) និងអង្គការសង់ត្រាល់ បានចុះសួរសុខទុក្ខពលករកម្ពុជាជាង ៤០០នាក់ ក្នុងករណីផ្ទុះសេខ្សែភ្លើង បណ្តាលឱ្យភ្លើងឆេះនៅរោងចក្រ ខូចខាតទាំងស្រុង។

ជុំវិញរឿងនេះ មន្ត្រីគម្រោងនៃអង្គការសង់ត្រាល់ ប្រចាំនៅប្រទេសថៃ លោក លឹង សុផុន លើកឡើងថា ពលករពិតជាមានការត្អូញត្អែរពីទុក្ខលំបាករបស់ពួកគាត់ ។ លោកអះអាងថា ពលករ ព្រួយបារម្ភថា ក្រោយបញ្ហានេះកើតឡើង មិនដឹងទៅធ្វើការនៅទីណានោះទេ ព្រោះថា កន្លែងធ្វើការកន្លងមកនេះ គឺបើកប្រាក់ខែទៀតទាត់មានថ្ងៃសម្រាកត្រឹមត្រូវ និងគោរពសិទ្ធិពលករបានល្អ ហើយម្យ៉ាងបើសិនជាទៅធ្វើការកន្លែងផ្សេង គឺត្រូវធ្វើឯកសារជាច្រើន៖ «ពលករមួយចំនួនគាត់ស្នើសុំ អោយខាងអង្គការ ខាងស្ថាប័នរដ្ឋ ខាងស្ថានទូតហ្នឹង ជួយដោះស្រាយពួកគាត់ ដើម្បីកុំឱ្យទុកពួកគាត់យូរអ៊ីចឹងណា ។ ព្រោះអីកាលណាទុកយូរវាអត់មានលុយសម្រាប់ចំណាយប្រចាំថ្ងៃផង ហើយនឹងការចំណាយប្រចាំថ្ងៃវាច្រើន ដូចជាថ្លៃបន្ទប់ថ្លៃអី និងថ្លៃហូបចុកក៏ច្រើនដែរ អ៊ីចឹងហើយបន្ទាប់ពីការរែកញែកអី...ស្នើសុំពីពលករខ្មែរមានចំនួនច្រើន ហើយខាងរោងចក្រក៏គេសុំពេលនៅថ្ងៃទី១៥ គេនិងប្រាប់ចម្លើយ ថាតើគួរយកពួកគាត់ទៅធ្វើការនៅសាខាផ្សេង ឬក៏ឱ្យពួកគាត់ធ្វើការនៅកន្លែងបណ្តោះអាសន្នសិន»។ លោក លឹង សុផុន បន្តថា រោងចក្រនេះ មានពលករខ្មែរ ៦៥ភាគរយ ហើយមានចំនួនពលការិនី ច្រើនជាងពលករជាបុរស ហើយ

ត្រូវបានអគ្គីភ័យឆាបឆេះថ្ងៃទី៥ មិថុនា ដោយផ្ទុះខ្សែភ្លើងឆេះ។ លោកបន្ថែមថា តំណាងស្ថានទូតកម្ពុជានៅថៃ កំពុងតែបន្តនីតិវិធីការងារជាមួយតំណាងរោងចក្រ ដើម្បីសម្រួលដល់ពលកររងគ្រោះ៕

## ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២

### ការឆ្លងដែនតាមច្រកខេត្តបន្ទាយមានជ័យ កំពុងមមាញឹក ខណៈការធ្វើប័ណ្ណព្រំដែនកើនឡើង

https://btv.com.kh/ 2022/06/17 01:16:44 pm

បន្ទាយមានជ័យ៖ បច្ចុប្បន្ន ស្ថានភាពនៃការឆ្លងដែនចេញចូលប្រទេសថៃ តាមច្រកខេត្តបន្ទាយមានជ័យ ពិសេសតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត កំពុងមានការមមាញឹកខ្លាំង ហើយប្រជាពលរដ្ឋទៅធ្វើប័ណ្ណព្រំដែន ក៏មានការកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃ ។ នេះបើតាមការឱ្យដឹងពីអភិបាលខេត្តបន្ទាយមានជ័យ។

ឯកឧត្តម អ៊ុំ រាត្រី អភិបាលខេត្តបន្ទាយមានជ័យ កាលពីរសៀលថ្ងៃទី១៦ ខែមិថុនា ម្សិលមិញ បានប្រាប់ BTVថា ស្ថានភាពឆ្លងដែនរបស់ពលរដ្ឋចេញចូលប្រទេសថៃ កំពុងមានការកើនឡើង ហើយទោះបីមានការបើកច្រកទ្វារ អន្តរជាតិប៉ោយប៉ែត ក៏នៅមានពលករឆ្លងដែនមកពីថៃ តាមច្រកអូរបីជាន់ ស្ថិតក្នុងស្រុកអូរជ្រៅផងដែរ។ ចំណែកការធ្វើប័ណ្ណព្រំដែនវិញ មានការកើនឡើងខ្លាំង គឺចាប់តាំងពីថៃបើកព្រំដែន មានអ្នកទៅធ្វើជាច្រើនម៉ឺននាក់ហើយ ។ ឯកឧត្តម បានបញ្ជាក់ថា ទោះស្ថានភាពនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩បានល្អប្រសើរវិញក្តី ប៉ុន្តែវិធានការទប់ស្កាត់ការឆ្លងជំងឺនេះតាមច្រកព្រំដែន នៅតែបន្តពង្រឹង រួមទាំងមានការអប់រំផ្សព្វផ្សាយ បន្ថែមអំពីការបង្ការ និងអំពាវនាវដល់ពលករទៅទទួលការចាក់វ៉ាក់សាំង នៅតាមទីតាំងដែលអាជ្ញាធររៀបចំរួចរាល់។

កន្លែងមកឯកឧត្តម អ៊ុំ រាត្រី បានឲ្យដឹងថា ដោយសារមានកំណើនពលរដ្ឋឆ្លងដែនចេញចូល ប្រទេសថៃនោះ អាជ្ញាធរខេត្ត គ្រោងពិភាក្សាជាមួយភាគីថៃ បើកច្រកតំបន់២ទៀត គឺច្រកម៉ាឡៃ និងច្រកបឹងត្រកួន ។ នៅក្នុងខេត្តបន្ទាយមានជ័យមានកន្លែងធ្វើប័ណ្ណព្រំដែន ចំនួន២កន្លែង ទី១. នៅច្រកចេញចូលតែ មួយ ក្នុងបរិវេណសាលាខេត្ត និងមួយកន្លែងទៀត នៅក្រុងប៉ោយប៉ែត។ បើតាមរបាយការណ៍រដ្ឋបាលខេត្តបន្ទាយមានជ័យ កាលពីខែមេសា មានអ្នកធ្វើប័ណ្ណព្រំដែនចំនួនជាង ១ម៉ឺន៩ពាន់ប័ណ្ណ និងខែឧសភា មានចំនួនជាង ១ម៉ឺន៨ពាន់ប័ណ្ណ ៕ អត្ថបទ៖ បាន សុខរិទ្ធិ

### តុលាការជម្រះ បណ្តឹងឧទ្ធរណ៍ ស្ត្រីជាប់ចោទវៀតណាមម្នាក់ ជាប់ពាក់ព័ន្ធការជួញដូរមនុស្ស និង លក់ក្មេងស្រីខ្មែរចំនួន២នាក់ នៅខេត្តកណ្តាល

https://dap-news.com/ ByPH104Posted on June 21, 2022

**ភ្នំពេញ: ស្ត្រីជាប់ចោទវៀតណាម ម្នាក់ កាលពីថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០២២ ត្រូវបាន សាលាឧទ្ធរណ៍រាជធានីភ្នំពេញ ធ្វើការជំនុំជម្រះលើបណ្តឹង ឧទ្ធរណ៍របស់នាង ជាប់ពាក់ព័ន្ធនឹងការចាប់ពង្រត់កុមារីខ្មែរ ចំនួន២នាក់ ម្នាក់មានអាយុ ៧ ឆ្នាំ និង ម្នាក់ទៀត មានអាយុ ៩ ឆ្នាំ ពីក្រុងបាវិត ខេត្តស្វាយរៀង នាំមកលក់អោយ ក្រុមគ្រួសារវៀតណាម នៅក្នុងស្រុកកោះធំ ខេត្តកណ្តាល ព្រំដែនកម្ពុជាវៀតណាម ប្រព្រឹត្ត នៅក្នុងអំឡុងខែ មេសា ឆ្នាំ ២០១៩ ។**

លោក ប៉ុល សំអឿន ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ បានថ្លែងអោយដឹងនៅក្នុង អង្គសវនាការការថា ជាប់ចោទ ជនជាតិវៀតណាម រូបនេះ មាន ឈ្មោះ ង្វៀង លីលឿង ភេទស្រី អាយុ ៣៥ឆ្នាំ មុខរបរមិនពិតប្រាកដ មានទីលំនៅ មុខចាប់ខ្លួន នៅក្រុងបាវិត ខេត្តស្វាយរៀង។ ជនជាប់ចោទ ឈ្មោះ ង្វៀង លីលឿង ត្រូវបានសាលាដំបូងខេត្តស្វាយរៀង កាលពីថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០២០ កាត់ទោស ដាក់ពន្ធនាគារ កំណត់ ១៥ ឆ្នាំ និង បង្គាប់ឱ្យ

សងថ្លៃ ជំងឺចិត្ត ចំនួន ២លានរៀល ឱ្យ ទៅកុមារីខ្មែរ រងគ្រោះ ក្នុងម្នាក់ៗ ។ ជនជាប់ចោទត្រូវបាន តំណាងអយ្យការ ចោទប្រកាន់ពីបទ: នាំចេញដោយមិនស្របច្បាប់ ដោយមានគោលដៅ តាមបញ្ញត្តិមាត្រា ១១ នៃ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរ មនុស្សនិងការធ្វើអាជីវកម្មផ្លូវភេទ ប្រព្រឹត្តនៅខេត្តស្វាយរៀង និង ខេត្តកណ្តាល កាលពីអំឡុងខែ មេសា ឆ្នាំ ២០១៩។

ស្ត្រីជាប់ចោទ ត្រូវបានចាប់ឃាត់ខ្លួន កាលពីថ្ងៃទី ៧ ខែ មេសា ឆ្នាំ ២០១៩ នៅស្រុកកោះធំ ខេត្តកណ្តាល តាមបណ្តឹង របស់ ឪពុកម្តាយកុមារីរងគ្រោះ បន្ទាប់នាង បានចាប់ពង្រត់ ពីក្រុមគ្រួសារ នៅក្រុងបាវិត និង នាំក្មេងស្រីរងគ្រោះ មកលក់ នៅក្នុងស្រុកកោះធំ ក្នុង តម្លៃ ម្នាក់ៗ ៧០០ដុល្លារអាមេរិក។

សាលាឧទ្ធរណ៍ រាជធានីភ្នំពេញ នឹងប្រកាសប្រកាសសាលដីកា លើសំណុំរឿងក្តីព្រហ្មទណ្ឌនេះ នៅព្រឹកថ្ងៃទី ៦ ខែ កក្កដា ឆ្នាំ ២០២២ ៕ ដោយ: លីហ្សា

## ពលរដ្ឋខ្មែរនៅតែបន្តលួចឆ្លងដែនទៅធ្វើការនៅថៃ ខណៈកម្ពុជាកំពុងខ្វះកម្លាំងពលកម្ម

https://www.postkhmer.com/ ឡាយ សាមាន | Publication date 22 June 2022 | 09:19 ICT

**ភ្នំពេញ:** លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារបានអះអាងថា បច្ចុប្បន្នកម្ពុជា មានការលំបាកក្នុងការរកកម្លាំងពលកម្ម ដើម្បីផ្គត់ផ្គង់នៅតាមសហគ្រាស និងរោងចក្រកាត់ដេរ ខណៈអាជ្ញាធរនៅតាមព្រំដែនបាននិយាយថា មានពលរដ្ឋខ្មែរជាច្រើននៅតែបន្តលួចឆ្លងដែនខុសច្បាប់ទៅរកការងារធ្វើនៅប្រទេសថៃ ដោយសារតែបញ្ហាជីវភាព និងជំពាក់បំណុលគេ។ លោក អ៊ិត សំហេង បានថ្លែងកាលពីពេលថ្មីៗនេះថា បច្ចុប្បន្នអត្រាមានការងារធ្វើនៅកម្ពុជាមានជាង ៩៦ ភាគរយ ស្របពេលដែលកម្ពុជាក៏នៅខ្វះកម្លាំងពលកម្មទៅលើផ្នែកមួយចំនួនផងដែរ។ លោកបញ្ជាក់ថា៖ «ឥឡូវនេះ យើងពិបាករកកម្លាំងពលកម្ម ដើម្បីផ្គត់ផ្គង់ឱ្យតាមសហគ្រាស និងរោងចក្រកាត់ដេរស្បែកជើង និងកសិកដ្ឋានធំ ចម្ការចេក ចម្ការកៅស៊ូនៅខ្វះកម្លាំងពលកម្ម នៅតាមគ្រឹះស្ថាន សេវាកម្មធនាគារ ភោជនីយដ្ឋាន ក៏នៅខ្វះកម្លាំងពលកម្មដែរ អ៊ីចឹងមានតម្រូវការច្រើន»។ លោកគូសបញ្ជាក់ថា ស្របពេលដែលកម្ពុជានៅខ្វះកម្លាំង ហើយនៅតែមានពលរដ្ឋធ្វើចំណាកស្រុកទៅធ្វើការនៅក្រៅប្រទេសនោះគឺជាសិទ្ធិរបស់ពលរដ្ឋ។

បច្ចុប្បន្នពលរដ្ឋខ្លះនៅតែលួចឆ្លងដែនខុសច្បាប់ទាំងគ្រួសារទាំងប្តីប្រពន្ធ កូនតូចៗ ដោយជឿតាមការញុះញង់របស់មេខ្យល់ ដែលបានសន្យារកការងារឱ្យធ្វើនៅថៃជាថ្នូរនឹងការផ្តល់ប្រាក់ទៅឱ្យមេខ្យល់ចន្លោះពី ៧០០ ទៅ ១ ០០០ បាត។ ការឆ្លងដែនខុសច្បាប់ទាំងនោះ ប្រឈមនឹងការឃាត់ខ្លួនពីសំណាក់កងកម្លាំងព្រំដែនទាំងសងខាង និងបញ្ហាផ្សេងៗទៀត ខណៈកម្លាំងការពារព្រំដែនទាំងខ្មែរ និងថៃបានរឹតបន្តឹងនៅតាមព្រំដែនចាប់តាំងពីមានជំងឺកូវីដ ១៩ រាតត្បាតមក។ មន្ត្រីនៅតាមខ្សែបន្ទាត់ព្រំដែនប្រចាំនៅខេត្តបន្ទាយមានជ័យបានឱ្យដឹងថា ជារឿយៗ បន្ទាប់ពីឃាត់ខ្លួន និងធ្វើការសាកសួរ ពលរដ្ឋទាំងនោះភាគច្រើនឆ្លើយថា គាត់មិនមានលទ្ធភាពធ្វើលិខិតឆ្លងដែនស្របច្បាប់ ហើយខ្លះទៀតថា ដោយសារជំពាក់បំណុលធនាគារ។

អ្នកស្រី ចាន់ វន្នី ជាកសិកររស់នៅក្នុងស្រុកបាណន់ ខេត្តបាត់ដំបងឱ្យដឹងថា អ្នកស្រី និងប្តីបានទៅធ្វើការនៅប្រទេសថៃដោយខុសច្បាប់តាំងពីមុនកូវីដ ១៩ រាតត្បាត ហើយបានសម្រេចចិត្តវិលត្រឡប់មកខ្មែរវិញ បន្ទាប់ពីកូវីដនៅថៃ មានការរីករាលដាលខ្លាំង។ តាមពិតអ្នកស្រី និងប្តីមិនចង់ទៅធ្វើការនៅថៃទាំងប្រថុយប្រថាននោះទេ ប៉ុន្តែដោយសារអត់ជម្រើស។ អ្នកស្រីនិយាយ៖ «ព្រោះការដាំដំឡូងមីមិនបានផល លិចទឹករលួយអស់ ហើយជំពាក់បំណុលគេច្រើន ដោយសារខ្ចីលុយគេទិញដី ទិញពូជ អ៊ីចឹងមានតែទៅថៃ ដើម្បីរកការងារធ្វើ ហើយរកលុយមកសងគេ»។ អំឡុងពេលនៅថៃអ្នកស្រីបានធ្វើការនៅរោងចក្រផលិតថង់ដោយទទួលបានប្រាក់កម្រៃប្រមាណ ១ ម៉ឺនបាត

(ប្រមាណ ២៨០ ដុល្លារអាមេរិក) ក្នុង ១ ខែ។ ប៉ុន្តែក៏ត្រូវចំណាយច្រើនផងដែរទៅលើការស្នាក់នៅ និងការហូបចុក។ ក្នុងនាមជាពលករខុសច្បាប់ដែលមានបទពិសោធបានសម្រេចចិត្តវិលត្រឡប់មករស់នៅធ្វើការក្នុងប្រទេសកម្ពុជាវិញ និងស្នើឱ្យពលរដ្ឋខ្មែរផ្សេងទៀត ដែលមានបំណងទៅធ្វើការនៅថៃ គួរធ្វើទៅតាមស្របច្បាប់។ អ្នកស្រីថា៖ «ពួកខ្ញុំខុសច្បាប់អ៊ីចឹងគឺរស់នៅពិបាកហើយបែបលាក់លៀមបំផុត ជាពិសេសនៅពេលតម្រួតថៃចុះត្រួតពិនិត្យម្តងៗ។ ធ្វើនៅថៃអស់រយៈពេល ៣ ឆ្នាំហើយសល់លុយតិចតួច ហើយពេលត្រឡប់មកវិញ បើជួបតម្រួតថៃ គេយកលុយអស់ទៀត អ៊ីចឹងខ្ញុំសម្រេចចិត្តរកការងារធ្វើនៅខ្មែរវិញហើយ»។

ជាមួយគ្នានេះដែរ ពលករ ១ រូបរស់នៅខេត្តបន្ទាយមានជ័យ ដែលទើបត្រឡប់ពីប្រទេសថៃមុនពេលចូលឆ្នាំខ្មែរ បានប្រាប់ភ្នំពេញប៉ុស្ដិ៍ ក្នុងលក្ខខណ្ឌសុំមិនបញ្ចេញឈ្មោះថា លោកមិនមានឯកសារគ្រប់គ្រាន់សម្រាប់ឆ្លងដែនតាមច្រកដែលស្របច្បាប់ទៅថៃវិញនោះទេ ដូច្នេះមានតែទៅតាមច្រករបៀង។ លោកថា៖ «ព្រោះបើទៅវិញគេត្រូវការលិខិតឆ្លងដែន និងឯកសារផ្សេងៗ អ៊ីចឹងខ្ញុំត្រឡប់ទៅវិញមានតែតាមច្រករបៀងហើយឱ្យអ្នកនាំផ្លូវ (មេខ្យល់) ៨ ០០០ បាត»។ លោកបានរៀបរាប់ថា៖ «ការឆ្លងដែនខុសច្បាប់ មិនងាយស្រួលនោះទេបង ជួបបញ្ហាច្រើនត្រូវឆ្លងកាត់ស្ទឹង អូរ ឡើងភ្នំចុះឡើង ពេលខ្លះភ្លៀងធ្លាក់រហូតក៏មាន តែធ្វើម៉េចបើអត់ជម្រើសមានតែប្រថុយ»។

គិតត្រឹមរយៈពេល ១ សប្តាហ៍ ដើមខែមិថុនានេះ ពលករខ្មែរជិត ៦០ នាក់ ដែលបម្រុងលួចឆ្លងដែនខុសច្បាប់ទៅប្រទេសថៃតាមច្រករបៀងខេត្តបន្ទាយមានជ័យត្រូវបានសមត្ថកិច្ចទប់ស្កាត់ទាន់ពេលវេលា និងបានណែនាំឱ្យបញ្ឈប់សកម្មភាពបែបនេះ ដែលនឹងអាចបង្កគ្រោះថ្នាក់ផ្សេងៗ។ ទាំងនេះគិតត្រឹមតែច្រករបៀងមួយនៅខេត្តបន្ទាយមានជ័យតែប៉ុណ្ណោះ មិនទាន់រាប់បញ្ចូលនៅតាមច្រករបៀងខេត្តបាត់ដំបង និងខេត្តពោធិ៍សាត់នៅឡើយទេ ដែលជារឿយៗតែងតែមានពលករខ្មែរលួចឆ្លងដែនខុសច្បាប់ទៅរកការងារធ្វើនៅប្រទេសថៃ។

លោក សួង សៅ មេបញ្ជាការវរសេនាតូច នគរបាលការពារព្រំដែនគោកលេខ ៨១៥ នៃខេត្តបន្ទាយមានជ័យបានឱ្យដឹងថា កម្លាំងព្រំដែនសហការជាមួយកម្លាំងប៉ុស្តិ៍ចំបក់ និងកម្លាំងយោធាផ្នែកសឹករងក្រុងប៉ោយប៉ែតបានចេញប្រតិបត្តិការក្នុងការទប់ស្កាត់ពលករបានជិត ៥៩ នាក់ក្នុងនោះស្រី ២១ នាក់ នាដើមខែមិថុនានេះ ខណៈដែលពួកគេកំពុងបម្រុងលួចឆ្លងដែនខុសច្បាប់ទៅប្រទេសថៃ។ លោកឱ្យដឹងថា ប្រតិបត្តិការនោះធ្វើឡើងនៅស្រុកម៉ាឡៃ ដោយនៅថ្ងៃទី ៦ មិថុនា ទប់ស្កាត់បាន ១៥ នាក់ និងថ្ងៃទី ៤ មិថុនា ទប់ស្កាត់បានរហូតដល់ ៤៤ នាក់។ លោកបន្តថា៖ «ក្នុងចំណោមពលករទាំងនោះមានមកពីខេត្តបន្ទាយមានជ័យ សៀមរាប បាត់ដំបង កំពត ព្រៃវែង ឧត្តរមានជ័យ កំពង់ស្ពឺ និងត្បូងឃ្មុំជាដើម ហើយពលករទាំងអស់ បន្ទាប់ពីធ្វើការសួរនាំ អប់រំ និងធ្វើការសន្យារួច គឺបានអនុញ្ញាតឱ្យវិលត្រឡប់ទៅលំនៅឋានវិញរៀងៗខ្លួន»។

នាយប៉ុស្តិ៍នគរបាលការពារព្រំដែនគោកក្បាលទំនប់ លោក រឿម ប៊ុនរិទ្ធ មានប្រសាសន៍ថា បច្ចុប្បន្នពលករនៅតែបន្តលួចឆ្លងដែនខុសច្បាប់ជាបន្តបន្ទាប់ ទោះបីសមត្ថកិច្ចធ្លាប់ផ្សព្វផ្សាយអប់រំ និងបានដាក់កម្លាំងការពារនៅព្រំដែនយ៉ាងណាក៏ដោយ។ លោកថា៖ «សមត្ថកិច្ចយើង ខំប្រឹងប្រែងទាំងយប់ទាំងថ្ងៃដើម្បីទប់ស្កាត់ និងបានណែនាំ អប់រំគាត់ឱ្យទៅតាមច្រកព្រំដែនស្របច្បាប់ ព្រោះទៅច្រកខុសច្បាប់វាប្រឈមគ្រោះថ្នាក់ច្រើន ដូចជាការគេចពីសមត្ថកិច្ច ឬគ្រោះថ្នាក់ផ្សេងៗ»។ តាមអ្វីដែលសមត្ថកិច្ចសួរនាំកន្លងមក ពលករទាំងនោះភាគច្រើនថា មិនមានលិខិតឆ្លងដែន និងខ្វះថវិកា ទើបពួកគេសម្រេចចិត្តឆ្លងដែនខុសច្បាប់ទាំងប្រថុយប្រថាន។ លោកថា៖ «ខ្លះជំពាក់លុយធនាគារទើបពលរដ្ឋនៅតែលួចឆ្លងដែន ទោះបីយើងខំទប់ស្កាត់ អប់រំយ៉ាងណា ក៏គាត់នៅតែឆ្លៀតពេលលួចឆ្លងដែន ហើយគាត់ជាពលរដ្ឋយើង អ៊ីចឹងគ្រាន់តែអប់រំណែនាំគាត់ឱ្យទៅតាមផ្លូវត្រូវ យើងមិនធ្វើទារុណកម្មដាក់ពិន័យទេ»។

លោក ហាម សំខាន់ អភិបាលស្រុកសំពៅលូន ខេត្តបាត់ដំបង បានថ្លែងថា នៅក្នុងស្រុករបស់លោក ពលករឆ្លងដែនខុសច្បាប់ហាក់បីដូចជាថមថយក្នុងរយៈពេលចុងក្រោយនេះបើប្រៀបធៀបកាលពីផ្ទុះកូវីដខ្លាំង។ យ៉ាងណាក្តី លោកថ្លែងថា ពលករដែលឆ្លងដែនខុសច្បាប់ទៅថៃដោយសារកត្តាជីវភាព និងចង់រកប្រាក់កម្រៃបន្ថែម ដើម្បីផ្គត់ផ្គង់គ្រួសារ។ លោកថា៖ «ពីមុនមានលួចឆ្លងទៅឆ្លងមកហើយកន្លងមកដែលយើងបានសួរគាត់ ដោយសារកត្តាជីវភាព គាត់ត្រូវតែរកមុខរបរ និងការងារផ្សេងៗ អ៊ីចឹងគាត់ត្រូវបង្ខំចិត្តទៅរកការងារធ្វើនៅថៃ ដោយសារគាត់ចង់បានកម្រៃខ្ពស់ អ៊ីចឹងត្រូវបង្ខំចិត្តទៅក្រៅ»។

លោក មឿន តុលា យកប្រតិបត្តិមជ្ឈមណ្ឌលសម្ព័នភាពការងារ និងសិទ្ធិមនុស្ស បានមានប្រសាសន៍ថា តាមអ្វីដែលលោកជួបសម្ភាសជាមួយពលករទាំងនោះ ភាគច្រើនកត្តាជីវភាពខ្វះខាត និងបន្ទុកធំមួយទៀត គឺជំពាក់បំណុលធនាគារ។ លោកថា៖ «ទី ១ ទីផ្សារការងារយើងនៅចង្អៀត ទី ២ ដោយសារពលករទាំងនោះនៅមានបន្ទុកសងបំណុលទៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដូច្នេះហើយជម្រើសមានតែមួយទេ គឺចំណាកស្រុកនោះឯង»។ លោកបន្តថា បច្ចុប្បន្ន ទោះបីសេដ្ឋកិច្ចក្នុងស្រុកមានការងើបឡើងវិញបន្តិចមែន ប៉ុន្តែទីផ្សារការងារអត់ទាន់បានទូលំទូលាយនៅឡើយទេ ហើយការងារខ្លះ មិនទាន់ឆ្លើយតបទៅនឹងតម្រូវការរបស់ពលរដ្ឋ។ លោកថា៖ «ឧទាហរណ៍ ការងារនៅការដ្ឋានសំណង់នៅកម្ពុជាទទួលបានច្រើនគួរសមដែរ ១ ថ្ងៃបាន ២ ម៉ឺន ឬលើសពីនេះ ប៉ុន្តែការងារនេះ អត់មានសន្តិសុខការងារជាក់លាក់មានន័យថា ពេលគាត់ឈប់សម្រាក ឬឈឺ គឺអត់មានប្រាក់ឈ្នួលទេ ប៉ុន្តែនៅថៃគេមាន»។ លោកបន្តថា មួយវិញទៀតការចំណាយប្រចាំថ្ងៃនៅក្នុងស្រុកខ្ពស់មិនអាចឆ្លើយតបទៅនឹងប្រាក់ចំណូលដែលជាហេតុធ្វើឱ្យប្រជាពលរដ្ឋសម្លឹងមើលការងារនៅខាងក្រៅច្រើនជាងការងារនៅក្នុងស្រុក។

យ៉ាងណាក្តី លោករដ្ឋមន្ត្រី អ៊ិត សំហេង ថ្លែងថា៖ «ទេសន្តរប្រវេសន៍ការងារគឺជាសិទ្ធិ ហើយក៏ជាឱកាសដែលរាជរដ្ឋាភិបាលបានផ្តល់ជូនដល់ប្រជាជន អ៊ីចឹងទេគឺការដែលចេញទៅធ្វើការនៅក្រៅប្រទេស គឺជាជម្រើសមួយរបស់ប្រជាពលរដ្ឋ។ យើងក៏អំពាវនាវ និងជម្រាបជូនដំណឹងថា នៅក្នុងប្រទេសមិនខ្វះការងារទេ ឱ្យតែបងប្អូនចង់ធ្វើ ប៉ុន្តែជម្រើសរបស់គាត់ចង់ទៅ»។ លោកបានបន្តទៀតថា ក្រសួងការងារក៏បានបង្កើតនូវប្រព័ន្ធបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដែលផ្តល់ឱកាសឱ្យប្រជាពលរដ្ឋកាន់តែច្រើន យុវជន យុវនារី កាន់តែច្រើនចូលរួមការសិក្សាអាចបង្កើននូវសមត្ថភាពផ្ទាល់របស់ខ្លួន។ លោកថា៖ «អ្វីដែលយើងរំពឹងទុកគឺថា យុវជនម្នាក់ ឬពលរដ្ឋម្នាក់មានជំនាញ ១ ជាក្តីសង្ឃឹម ដែលយើងអាចគិតថា នឹងមានអនាគតល្អហើយធនធានមនុស្សផ្នែកបច្ចេកទេសវិជ្ជាជីវៈរបស់យើងនឹងបានបង្កើនឡើង ឆ្លើយតបទៅនឹងការអភិវឌ្ឍ សេដ្ឋកិច្ច និងទាក់ទាញការវិនិយោគបរទេស»៕

## ក្រសួងសង្គមកិច្ចចុះ MoU ជាមួយអង្គការចំនួន ១២ ដើម្បីជួយកុមាររងគ្រោះ ងាយរងគ្រោះ និងជនពិការនៅកម្ពុជា

https://www.postkhmer.com/ វ៉ន ដារ៉ា | Publication date 22 June 2022 | 17:34 ICT

**ភ្នំពេញ៖** ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅថ្ងៃទី ២២ ខែមិថុនានេះ បានចុះហត្ថលេខាលើអនុស្សារណៈនៃកិច្ចព្រមព្រៀង (MoU) ជាមួយអង្គការចំនួន ១២ ដើម្បីជួយក្នុងវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាដោយផ្តោតសំខាន់លើ កុមាររងគ្រោះ ងាយរងគ្រោះ និងជនពិការនៅកម្ពុជារយៈពេល ៣ ឆ្នាំ ក្រោមថវិកាអនុវត្តគម្រោងសរុប ៦ ៤៩៩ ៦០៧ ដុល្លារសហរដ្ឋអាមេរិក។ពិធីចុះហត្ថលេខានៃកិច្ចព្រមព្រៀងនាពេលនេះបានរៀបចំឡើងនាថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០២២ ក្រោមអធិបតីភាព លោក គួច ចាន់នី អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមានការចូលរួមពីថ្នាក់ដឹកនាំអង្គការទាំង ១២ រួមនឹងមន្ត្រីរាជការពាក់ព័ន្ធរបស់ក្រសួងសង្គមកិច្ចជាច្រើនរូបទៀត។

លោក តូច ចាន់នី ថ្លែងក្នុងពិធីនេះថា ការចូលរួមសហការរបស់អង្គការដៃគូ ពិតជាសំខាន់ណាស់ ក្នុងការលើកកម្ពស់វិស័យសង្គមកិច្ចនៅកម្ពុជា។ លោកបានស្នើឱ្យក្រុមការងារក្រសួង មន្ទីរសង្គមកិច្ចនៅតាមបណ្ដារាជធានី-ខេត្ត និងអង្គការ ដែលសហការ នាពេលនេះរួមគ្នា ដើម្បីធ្វើការងារ ដោយយកចិត្តទុកដាក់ឱ្យបានខ្លាំងបំផុតតាមដែលអាចធ្វើបាន។ លោកថ្លែងថា៖ «សម្រាប់ក្រសួង សង្គមកិច្ច វិញនៅតែស្វាគមន៍ជានិច្ចជាមួយ ដៃគូពាក់ព័ន្ធ និងអង្គការនានា ដើម្បីជួយដល់ជនរងគ្រោះ និងងាយរងគ្រោះនៅកម្ពុជាឱ្យមានជីវភាព និងជីវិតរស់នៅល្អប្រសើរថែមមួយកម្រិតទៀត»។ លោកបញ្ជាក់ថា អង្គការទាំង ១២ នេះ មានសុពលភាពនៃកិច្ចព្រមព្រៀងគម្រោងជាមួយក្រសួងសង្គមកិច្ច មានរយៈពេល ៣ ឆ្នាំ ដែលមានថវិកាអនុវត្តគម្រោងសរុប ៦ ៤៩៩ ៦០៧ ដុល្លារសហរដ្ឋអាមេរិក ដែលថវិកាទាំងនេះមិនមែនជាថវិការបស់រដ្ឋាភិបាលទេ ប៉ុន្តែជាថវិការបស់អង្គការទាំងអស់នេះ ដែលទទួលបានតាមរយៈគម្រោងស្នើសុំរបស់ខ្លួន។

លោកបានឱ្យដឹងថា អង្គការទាំងនោះរួមមាន ១ អង្គការ Save the Children ២ សមាគមអភិវឌ្ឍន៍បច្ចេកទេសយុវវ័យខ្មែរ ៣ អង្គការ ទីកន្លែង អាស៊ីហ្វា ៤ អង្គការ ទាំងអស់គ្នាដើម្បីកម្ពុជា ៥ អង្គការ Project Change International ៦ អង្គការ កុមារពិភពលោក ៧ អង្គការដើម្បីអនាគតកុមារជនបទ ៨ អង្គការហ៊ើសធាលអន្តរជាតិ ៩ អង្គការ ក្រុមជុំនុំដំណឹងល្អពោរពេញកម្ពុជា ១០ អង្គការបេសកកម្ម ស៊ីនដ សម្រាប់កម្ពុជា ១១ អង្គការជីបូឌា មិត្តកុមារកម្ពុជា ១២ អង្គការ អូអាយស៊ីកម្ពុជា (OIC)។

បើតាមក្រសួងសង្គមកិច្ច អង្គការទាំង ១២ ដែលបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយក្រសួងសង្គមកិច្ចនាពេលនេះសុទ្ធសឹងតែជាអង្គការដែលបានចូលរួមចំណែកជួយដល់កុមាររងគ្រោះ ងាយរងគ្រោះ និងជនពិការក្រីក្រនៅតាមសហគម។ ក្រសួងបានឱ្យដឹងថា អង្គការទាំង ១២ នេះ នឹងអនុវត្តសកម្មភាពផ្សេងៗ ទៅតាមគម្រោង និងតំបន់របស់ខ្លួន ក្នុងនោះមានអង្គការមួយចំនួននឹងជួយកុមារលើការផ្ដល់អាហារប្រចាំថ្ងៃនៅមណ្ឌលសហគមន៍ និងជួយដល់កុមាររងគ្រោះ ងាយរងគ្រោះ និងជនពិការនៅកម្ពុជា ឱ្យទទួលបានការសិក្សា និងសម្ភារសិក្សាផងដែរ។ លោក តូច ចាន់នី បានឱ្យដឹងថា បច្ចុប្បន្នក្រសួងសង្គមកច្ចមិនទាន់មានទិន្នន័យសរុប កុមាររងគ្រោះ ងាយរងគ្រោះនៅទូទាំងប្រទេសនៅឡើយទេ ប៉ុន្តែក្រសួងមានទិន្នន័យដែលកុមារកំពុងស្នាក់នៅមណ្ឌលកុមារក្រោមការមើលថែរបស់ក្រសួង សង្គមកិច្ច និង អង្គការផ្នែកគាំពារកុមារនៅកម្ពុជា។

លោកបញ្ជាក់ថា៖ «មកដល់ពេលនេះមណ្ឌលថែទាំកុមាររងគ្រោះ និងងាយរងគ្រោះ នៅទូទាំងប្រទេសមានការថយចុះច្រើនកាលពី ២-៣ ឆ្នាំមុន មណ្ឌលថែទាំកុមារមានរហូតដល់ជាង ៤០០ មណ្ឌលនៅទូទាំងប្រទេស ប៉ុន្តែបច្ចុប្បន្នទូទាំងប្រទេសមានតែជាង ១៩០ មណ្ឌលទេ ក្នុងនោះមណ្ឌលរបស់រដ្ឋមានចំនួន ២១ និងមានកុមាររងគ្រោះ និងងាយរងគ្រោះប្រមាណ ៨ ពាន់នាក់»៕

## ពលករខ្មែរនៅថៃប្រឈមបញ្ហាជីវភាព ដោយសារមិនបានប្រាក់សំណងក្រោយថៅកែថៃបញ្ឈប់ការងារ

https://www.rfa.org/ ដោយ ជីវីតា 2022.06.21

ពលករខ្មែរជាច្រើននាក់ធ្វើការនៅប្រទេសថៃមានជីវភាពលំបាក ក្រោយពីពេលថៅកែជនជាតិថៃបញ្ឈប់ពីការងារ ដោយមិនបានផ្ដល់ប្រាក់សំណង ដែលធ្វើឱ្យពួកគេ គ្មានការងារធ្វើរកប្រាក់ដោះស្រាយជីវភាពប្រចាំថ្ងៃ។ មន្ត្រីសង្គមស៊ីវិល យល់ឃើញថា ពលករខ្មែរធ្វើការខុសច្បាប់តែងតែត្រូវបានថៅកែថៃកេងប្រវ័ញ្ចកម្លាំងពលកម្ម ហើយគ្មានអាជ្ញាធរខ្មែរណាដោះស្រាយ ពួកគាត់នោះទេ។ រោងចក្រដែលបញ្ឈប់ពលករទាំងនោះ ជារោងចក្រផលិត

គ្រឿងបន្លាស់ម៉ាស៊ីនត្រជាក់ និងគ្រឿងអេឡិចត្រូនិក ដែលស្ថិតនៅ ខេត្តរះយ៉ង (Rak Yorng) ។ ការបញ្ឈប់នេះធ្វើឱ្យពលករខ្មែរជិត ៧០នាក់អត់ការងារ និងគ្មានប្រាក់បង់ថ្លៃទឹកថ្លៃភ្លើងថ្លៃបន្ទប់ជួលថ្លៃថែទាំសុខភាព និងមិនមានប្រាក់ផ្ញើជូនគ្រួសារនៅកម្ពុជា ដើម្បីសងធនាគារ។

ពលការិនីខ្មែរធ្វើការរោងចក្រនៅខេត្តរះយ៉ង (Rak Yorng) លោកស្រី ស៊ិន ដា ប្រាប់វិទ្យុអាស៊ីសេរីនៅថ្ងៃទី ២០មិថុនា ថាលោកស្រីព្រួយបារម្ភពីជីវភាពខ្វះខាតក្នុងពេលស្នាក់នៅក្នុងប្រទេសថៃ ។លោកស្រី បន្តថា ប្រសិនបើលោកស្រី នៅតែបន្តគ្មានការងាររយៈពេលយូរទៅមុខទៀត នឹងធ្វើឱ្យប៉ះពាល់ដល់ការរស់នៅកាន់តែខ្លាំង៖ «ដូចថាយើងពលករខុសច្បាប់អ៊ីចឹងទៅ គឺគេអត់សូវយកចិត្តទុក្ខដាក់យើង ដល់ពេលអត់ការងារគឺជំរុះចោលអញ្ចឹងទៅ គេអត់ខ្វល់ហាស់ ! និយាយរួមទៅគេអត់ខ្វល់ពីយើង ថាយើងទុក្ខលំបាកម៉េចគេអត់ខ្វល់ សំខាន់គឺគេអត់មានការងារអោយធ្វើ អោយយើងរកការងារធ្វើខ្លួនឯងទៅ ″ ។ លោកស្រី ស៊ិន ដា អំពាវនាវដល់រដ្ឋាភិបាលជួយដល់ពលករខ្មែរខុសច្បាប់ ឱ្យមានសិទ្ធិស្របច្បាប់ ដើម្បីងាយស្រួលរកការងារធ្វើក្នុងប្រទេសថៃ និងកុំឱ្យក្រុមមេខ្យល់ជនជាតិខ្មែរ និងថៃចេះតែបោកប្រាស់កម្លាំងពលកម្មរបស់ពលរដ្ឋខ្មែរនៅប្រទេសថៃបន្តទៀត។

ចំណែកពលករខ្មែរម្នាក់ធ្វើការរោងចក្រនៅខេត្តរះយ៉ង លោក មឿន លួន ថ្លែងថា លោកជួបការលំបាកខ្លាំងព្រោះមិនមានការងារធ្វើជិត២ខែមកហើយនៅក្នុងប្រទេសថៃ ក្រោយពីរោងចក្របញ្ឈប់លោកពីការងារ ។ លោកបន្តថា បញ្ហាចំពោះមុខពេលនេះ គឺលោកត្រូវចំណាយទៅលើការជួលបន្ទប់ ថ្លៃទឹក ថ្លៃភ្លើង ថ្លៃអាហារប្រចាំថ្ងៃ និងថ្លៃធនាគារនៅស្រុកខ្មែរជាដើម៖ «មិនជាគេដកចេញឬក៏»។

វិទ្យុអាស៊ីសេរីមិនអាចទាក់ទងមន្ត្រីស្ថានទូតខ្មែរប្រចាំប្រទេសថៃ ដើម្បីសុំការអធិប្បាយជុំវិញរឿងនេះបានទេនៅថ្ងៃទី២០ មិថុនា ដោយទូរស័ព្ទចូលគ្មានអ្នកទទួល។ ប៉ុន្តែកាលថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២២ អនុព័ន្ធការងារតំណាងស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ បានសហការជាមួយមូលនិធិលើកកម្ពស់សិទ្ធិនិងគុណភាពជីវិតពលករ (LPN) និងអង្គការសង់ត្រាល់ បានចុះសួរសុខទុក្ខពលករកម្ពុជាជាង ៤០០នាក់ ហេតុការណ៍ភ្លើងឆេះនៅរោងចក្រម៉ាស្ទ័រ ហ្វូត(Master Wood) ដោយមានការខូចខាតទាំងស្រុង ដែលស្ថិតនៅតំបន់និគមផាត់តាណា ខេត្តរ៉ាក់យ៉ង កាលពីថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២២ ។

ជុំវិញរឿងនេះ មន្ត្រីគម្រោងនៃអង្គការសង់ត្រាល់ ប្រចាំនៅប្រទេសថៃ លោក លឹង សុផុន ថ្លែងថាលោកបានចូលរួមជាមួយអង្គការ (FAR) Foundation for AIDs Rights និង មូលនិធិលើកកម្ពស់សិទ្ធិ និងគុណភាពជីវិតពលករ (LPN) សហការគ្នាចុះទៅដល់កន្លែងពលករ ហើយបានអប់រំណែនាំពីសិទ្ធិ និងអត្ថប្រយោជន៍ផ្សេងៗដល់ពលករទាំងនោះ ។ លោក លឹង សុផុន មើលឃើញថា ក្រុមពលករទាំងនោះកំពុងជួបការលំបាកដោយគ្មានប្រាក់បង់ថ្លៃបន្ទប់ជួល ថ្លៃទឹក ថ្លៃភ្លើង និងគ្មានប្រាក់សម្រាប់ដោះស្រាយជីវភាពគ្រួសារជាដើម ។ លោកបន្តថា ពលករពិបាកក្នុងការចេញទៅរកការងារធ្វើនៅកន្លែងផ្សេង ដោយសារពួកគាត់ធ្វើការងារដោយខុសច្បាប់ ប្រឈមនឹងការបោកប្រាស់កម្លាំងពលករពីក្រុមមេខ្យល់នៅប្រទេសថៃ៖ «យើងនឹងស្វែងរកនីតិវិធីណា ដែលដើម្បីឱ្យបងប្អូនទទួលបានយុត្តិធម៌ ហើយមួយវិញទៀត រឿងហ្នឹងវាសាំញ៉ាំដែរ ទាក់ទងទៅរឿងថៅកែសាប់(អ្នកនាំពលករ)ផង ថៅកែរោងចក្រផង ហើយណាមួយទៀតទាក់ទងទៅរឿងមេការខាងសាប់ហ្នឹងឯង គេយកឯកសារគាត់ទៅដើររឿង ធ្វើប័ណ្ណការងារ(បាត់) ធ្វើវីសាហ្នឹង ក៏វាមិនទាន់ត្រឹមត្រូវតាមច្បាប់ហាស់ ! មើលទៅឃើញថា បើសិនត្រឹមត្រូវតាមច្បាប់គឺបងប្អូនពលករហ្នឹងមានកាតរាប់ប្រកាន់សង្គម(ធានារ៉ាប់រងសង្គម) ហ្នឹងហើយ»។

លោក លឹង សុផុន បន្ថែមថា នៅតាមរោងចក្រមួយចំនួន មានភាពមិនប្រក្រតី ពេលពលករបើកប្រាក់ខែម្តងៗ គឺគេតែងកាត់ប្រាក់ទៅលើរបបសង្គម និងថ្លៃតម្រួត។ កន្លងមកពលករខ្មែរធ្វើការនៅប្រទេសថៃ តែងជួបការលំបាកជាច្រើន ដោយខ្លះគ្រោះថ្នាក់ចរាចរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម និងមួយចំនួនក៏ត្រូវថៅកែធ្វើបាប និង

ការងារមិនបើកប្រាក់ឈ្នួលជាដើម ។ របាយការណ៍ក្រសួងការងារឆ្នាំ២០២១ បង្ហាញថា ពលករកម្ពុជាធ្វើការងារស្របច្បាប់និងមិនស្របច្បាប់ធ្វើការនៅប្រទេសថៃមាន ១លាន២សែននាក់ ប៉ុន្តែអង្គការសង់ត្រាល់បង្ហាញថា ពលករខ្មែរធ្វើការងារស្របច្បាប់ និងមិនស្របច្បាប់មានប្រមាណ ២លាននាក់ កំពុងធ្វើការនៅប្រទេសថៃ៕

## នៅព្រឹកថ្ងៃអាទិត្យ អាជ្ញាធរស្រុកសំពៅលូន បន្តទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ពីប្រទេសថៃ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ

https://gdlf-kh.com/ 2022/06/26/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅវេលាម៉ោង១០និង០០នាទី នាថ្ងៃអាទិត្យ ១២រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ម៉ង់ ស៊ី មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោក លេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍គីឡូ១៣ ចំនួន០៣នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក ម៉ឺង-ម៉េត (នាយប៉ុស្តិ៍) សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូន ចំនួន០៣នាក់ ដឹកនាំដោយលោកនាយចំណង់ ជា យ៉ាន (មេបញ្ជាការកងអនុសេនាតូច) កម្លាំងយោធាវរសេនាតូច៥៣៣ ចំនួន០៣នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក ពៅ-ចំរើន (មេបញ្ជាការរងកងអនុសេនាធំ) បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន១លើក សរុបចំនួន១១នាក់ ស្រី៤នាក់ ក្មេង២នាក់ ក្មេងស្រី១នាក់។ ក្រោយពីទទួលបាន កម្លាំងយើងបានធ្វើកត់ឈ្មោះ ចុះកំណត់ហេតុប្រចាំថ្ងៃ អប់រំណែនាំ រួចបានប្រគល់បងប្អូនទាំងអស់ឱយទៅក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូនធ្វើពិនិត្យ និងស្វែនប័ណ្ណចាក់វ៉ាក់សាំងចេញត្រឹមត្រូវទាំងអស់ បន្ទាប់មកក្រុមគ្រូពេទ្យបានអនុញ្ញាតឲ្យបងប្អូនត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួន។

# ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២២

## ការបៀតបៀនផ្លូវភេទលើកុមារ
## តាមប្រព័ន្ធអ៊ីនធឺណែតស្ថិតក្នុងហានិភ័យខ្ពស់ ខណៈកូវីដ១៩

https://www.rfi.fr/km/ ចុះផ្សាយនៅថ្ងៃ៖ 28/06/2022

មន្ត្រីរដ្ឋាភិបាលកម្ពុជា និងក្រុមអង្គការសិទ្ធិកុមារបានទទួលស្គាល់ថា ការបៀតបៀនផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធឺណែតគឺកំពុងតែធ្វើឲ្យការព្រួយបារម្ភកាន់តែខ្លាំងឡើង ខណៈការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណែតកាន់តែកើននៅអំឡុងពេលកូវីដ១៩។ ការលើកឡើងនេះ គឺក្នុងសិក្ខាសាលាស្តីពីការជំរុញការចូលរួមរបស់ក្រុមហ៊ុនបច្ចេកវិទ្យាក្នុងកិច្ចការពារកុមារលើប្រព័ន្ធអនឡាញ នៅថ្ងៃអង្គារនេះ ខណៈកុមារកម្ពុជាប្រមាណ៣លានលានកំពុងប្រើអ៊ីនធឺណែតដើម្បីសិក្សានៅអំឡុងកូវីដ១៩ ក្នុងនោះការរាយការណ៍ពីការរំលោភបំពានផ្លូវភេទមានជាង៤០ម៉ឺនករណី។ ការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណែតដើម្បីកុមារសិក្សាដោយសារតែកូវីដ១៩ បានធ្វើឲ្យមានបញ្ហាប្រឈមជាច្រើនដល់កុមារដូចជា ការគំរាមកំហែង ការបោកប្រាស់ ការបៀតបៀនផ្លូវភេទ និងការធ្វើបាបពីជនមិនស្គាល់មុខលើសតិអារម្មណ៍ និងស្មារតីរបស់ពួកគេ។

ករណីនៃការរាយការណ៍ពីការរំលោភបំពានផ្លូវភេទចំពោះកុមារលើបណ្តាញអ៊ីនធឺណែត បានកើនឡើង ៣៥% នៅឆ្នាំ២០២១ ខ្ពស់ជាងឆ្នាំ២០២០ ពោលកើនឡើងពី២០លានទៅ២៩លានករណី ក្នុងនោះនៅកម្ពុជា មានជាង៤០ម៉ឺនករណី កើនលើសជាងទ្វេដង។ នេះបើតាមការសិក្សារបស់អង្គការអាមេរិកាំងមួយឈ្មោះកាត់ថា (NCMEC)។ នៅកម្ពុជាកិច្ចពិគ្រោះយោបល់ជាមួយយុវជន និងកុមារដែលធ្វើឡើងនៅឆ្នាំ២០២០ ដោយសម្ព័ន្ធអង្គការសិទ្ធិកុមារ បានរកឃើញថា ១៥% នៃកុមារដែលចូលរួមពិគ្រោះយោបល់ បានរាយការណ៍ថា ពួកគេធ្លាប់មានជនមិនស្គាល់មុខ ទាក់ទងតាមបណ្តាញសង្គម។ កុមារ២%បាននិយាយទៀតថា ពួកគេធ្លាប់ត្រូវបានគេស្នើសុំចែករំលែករូបភាព សកម្មភាពមិនសមរម្យ និងរូបភាពបែបស្និទស្នាល នៅមុខកាមេរ៉ាដែលភ្ជាប់នឹងអ៊ីនធឺណែត។

បើតាមលោក នាង ម៉ៅ អគ្គនាយកបច្ចេកទេសនៃក្រសួងប្រៃសណីយ៍ នៅកម្ពុជាថ្មីៗនេះ ក៏សង្កេតឃើញមានការជួញដូររូបភាពអាសអាភាសកើតឡើងជាបន្តបន្ទាប់លើបណ្តាញសង្គម។ លោកគូសបញ្ជាក់ថា ដោយមានកំណើនចរាចរណ៍ករណីរំលោភបំពាន និងផ្សព្វផ្សាយរូបភាពអាសអាភាស របស់កុមារលើបណ្តាញអ៊ីនធឺណែត ក្រុមហ៊ុនបច្ចេកវិទ្យាធំៗជាច្រើនលើពិភពលោកបាននិងកំពុងចាត់វិធានការទប់ស្កាត់ ដោយប្រើប្រាស់បច្ចេកវិទ្យាផ្សេងទៀតដូចជាការប្រើប្រាស់ប្រព័ន្ធសញ្ញានិមិត្ត ដើម្បីពិនិត្យរូបភាព និងកំណត់អត្តសញ្ញាណជនរងគ្រោះ ជនល្មើស និងទីតាំង។

លោក Anirban Chatterjee តំណាង UNICEF ប្រចាំកម្ពុជាបានគូសបញ្ជាក់ថា កំណើននៃភាពងាយគ្រោះទៅលើកុមារនៅតាមអ៊ីនធឺណែត គឺដោយសារតែពិភពលោកឈានទៅប្រើប្រាស់ប្រព័ន្ធឌីជីថលយ៉ាងឆាប់រហ័ស។ លោកអះអាងថា UNICEF ប្តេជ្ញាបន្តសហការជាមួយរដ្ឋាភិបាល និងវិស័យឯកជន ក្នុងការធានាថា កុមារកម្ពុជាគ្រប់រូប ទទួលបានសារប្រយោជន៍ពីពិភពឌីជីថល ទន្ទឹមនឹងទទួលបានការការពារចៀសផុតពីគ្រោះថ្នាក់តាមប្រព័ន្ធអនឡាញ៕

## វៀតណាមជួយសង្គ្រោះពលរដ្ឋ ៤០០នាក់ដែលបានចាញ់បោកមកធ្វើការខុសច្បាប់នៅកម្ពុជា

https://www.khmertimeskh.com/ Khmer Times June 28, 2022

អាជ្ញាធរវៀតណាម និងកម្ពុជា បានសហការគ្នាបញ្ជូនពលរដ្ឋវៀតណាម ៤០០នាក់ ដែលត្រូវបានចាញ់បោក និងត្រូវបានគេយកមកលក់នៅកម្ពុជា។ មកទល់ពេលនេះ អាជ្ញាធរវៀតណាម និងកម្ពុជា បានធ្វើការរួមគ្នាដើម្បីពិនិត្យករណីដែលជនជាតិវៀតណាមត្រូវបានក្រុមជួញដូរមនុស្សនាំមកកម្ពុជា។

អ្នកនាំពាក្យក្រសួងការបរទេសលោកស្រី Le Thi Thu Hang បានប្រាប់សារព័ត៌មានកាលពីថ្ងៃអាទិត្យថា កិច្ចសហការគ្នានេះបានបណ្តាលឱ្យជនជាតិវៀតណាមជិត៤០០ នាក់ត្រូវបានជួយសង្គ្រោះ និងនាំយកមកផ្ទះវិញ។ មួយរយៈចុងក្រោយនេះ ត្រូវបានគេរាយការណ៍កាន់តែច្រើនឡើងថា មានជនជាតិវៀតណាមជាច្រើនត្រូវបានបោកបញ្ឆោតឱ្យមកធ្វើការនៅកម្ពុជា។ ក្នុងករណីភាគច្រើន ក្រុមជួញដូរបានផ្សព្វផ្សាយសេវាកម្មរបស់ពួកគេនៅលើ Facebook និង Zalo ដែលជាកម្មវិធីផ្ញើសារ និងហៅទូរសព្ទរបស់វៀតណាម ដោយផ្តោតលើមនុស្សដែលមានអាយុគ្រប់ធ្វើការ ប៉ុន្តែមិនមានការងារ ដោយសន្យាថានឹងអោយការងារល្អជាមួយនឹងប្រាក់ខែរហូតដល់រាប់ពាន់ដុល្លារ។ ជាធម្មតា ជនរងគ្រោះត្រូវបានរត់ពន្ធចូលប្រទេសកម្ពុជាតាមផ្លូវខុសច្បាប់ ហើយត្រូវបានបញ្ជូនទៅធ្វើការនៅក្រុមហ៊ុនដែលគ្រប់គ្រងដោយជនបរទេស។

ម្ចាស់ក្រុមហ៊ុនបែបនេះបង្គាប់អោយបុគ្គលិកវៀតណាមរបស់ពួកគេឱ្យបង្កើតគណនីប្រព័ន្ធផ្សព្វផ្សាយសង្គមផ្សេងៗដោយបន្លំជាគេហទំព័រពាណិជ្ជកម្មឬវិនិយោគហិរញ្ញវត្ថុដើម្បីបោកបញ្ឆោតអតិថិជនដែលមិនមានការសង្ស័យ។

បើមិនព្រមធ្វើទេ អ្នកធ្វើការជនជាតិវៀតណាមទាំងនោះនឹងត្រូវគេវាយធ្វើបាប រួមទាំងបង្អត់អាហារផងដែរ។ ក្នុងករណីផ្សេងទៀត អ្នកដែលត្រូវបានគេត់ពន្ធមកកម្ពុជារួមមានស្ត្រីវ័យក្មេងត្រូវបានបង្ខំឱ្យធ្វើជាស្ត្រីពេស្យាចារ។ ជនរងគ្រោះបានប្រាប់ប៉ូលីសថា អ្នកណាដែលចង់ត្រឡប់ទៅប្រទេសវៀតណាម ត្រូវតែទាក់ទងក្រុមគ្រួសាររបស់ពួកគេជាមុនសិន ហើយបង់ប្រាក់ធានាប្រហែល ៨០-១០០ លានដុង (៣,៤៤៦ ដុល្លារ)៕ *e.vnexpress.net*

## សាកស.៣មនុស្សជាង៤០នាក់រកឃើញក្នុងឡានកុងតឺន័រ

https://kohsantepheapdaily.com.kh/ ២៨ ខែ មិថុនា ឆ្នាំ ២០២២ ម៉ោង ០៩:៤០

មនុស្សយ៉ាងតិច ៤៦នាក់ដែលត្រូវគេជឿជាក់ថាជាជនអន្តោប្រវេសន៍ ត្រូវបានប្រទះឃើញស្លាប់នៅក្នុងរថយន្តកុងតឺណឺដែលគេប្លុងចោលនៅក្នុងទីក្រុង San Antonio នៃរដ្ឋ Texas។ មន្ត្រីអាមេរិកនិយាយថា មនុស្សចំនួន ១៦នាក់ រួមទាំងកុមារ ៤នាក់ផងត្រូវបានគេបញ្ជូនទៅកាន់មន្ទីរពេទ្យ។ អ្នកនៅរស់រានមានជីវិតទាំងនោះប្រឈមនឹងជំងឺដាច់សរសៃឈាមក្នុងខួរក្បាល និងអស់កម្លាំងដោយសារហប់ខ្យល់។ ទីក្រុង San Antonio ដែលមានចំងាយប្រហែល ២៥០គីឡូម៉ែត្រពីព្រំដែនប្រទេសមិចស៊ិចកូ គឺជាច្រកដ៏សំខាន់សម្រាប់អ្នករត់ពន្ធមនុស្ស។ អ្នកជួយដូរមនុស្សតែងតែប្រើប្រាស់រថយន្តដឹកទំនិញខ្នាតធំ ដើម្បីដឹកជញ្ជូនជនអន្តោប្រវេសន៍គ្មានឯកសារគ្រប់គ្រាន់បន្ទាប់ពីជួបពួកគេនៅក្នុងតំបន់ដាច់ស្រយាល នៅពេលពួកគេត្រូវធ្វើដំណើរឆ្លងកាត់ចូលទឹកដីអាមេរិក។

អភិបាលក្រុង San Antonio លោក Ron Nirenberg និយាយថា "ពួកគេមានក្រុមគ្រួសារ ហើយទំនងជាព្យាយាមស្វែងរកជីវិតដែលប្រសើរ"។ ប្រធានក្រុមពន្លត់អគ្គិភ័យក្នុងទីក្រុង San Antonio លោក Charles Hook បានថ្លែងប្រាប់អ្នកសារព័ត៌មានថា "យើងមិនបានគិតថាបើកទ្វាររថយន្តនោះ និងឃើញសាកស.៣ជាច្រើនក្នុងនោះសោះ។ ពួកយើងទៅធ្វើការវិញ ដោយមិនស្រម៉ៃថាមានរឿងបែបនោះឡើយ"។ លោកថ្លែងថា ម៉ាស៊ីនត្រជាក់នៅក្នុងរថយន្តកុងតឺណឺដែលត្រូវបានអ្នកបើកបរបោះបង់ចោលមិនដំណើរការ ហើយក៏មិនមានទឹកនៅក្នុងវាផងដែរ៕ (យោងតាមប្រភព៖ BBC)

# ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២

## ក្រសួងរកឃើញករណីបំពានផ្លូវភេទកុមារតាមអ៊ីនធឺណិតនៅកម្ពុជាកើនឡើង

https://www.postkhmer.com/ ឡាយ សាមាន | Publication date 29 June 2022 | 10:13 ICT

**ភ្នំពេញ:** ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍រកឃើញថា ករណីរំលោភបំពានផ្លូវភេទចំពោះកុមារលើបណ្ដាញអ៊ីនធឺណិតនៅកម្ពុជាក្នុងឆ្នាំ ២០២១ មានចំនួនប្រមាណ ៤០ ម៉ឺនករណី គឺកើនលើសទ្វេដងបើធៀបនឹងឆ្នាំ ២០២០ ហើយបានអំពាវនាវគ្រប់តួអង្គទាំងរដ្ឋ និងវិស័យឯកជនចូលរួមទប់ស្កាត់ទាំងអស់គ្នា។

របាយការណ៍ពីករណីនេះ ត្រូវបានដាក់បង្ហាញនៅក្នុងសិក្ខាសាលាចាប់ផ្ដើមគម្រោងស្ដីពី "ការជំរុញការចូលរួមរបស់ក្រុមហ៊ុនបច្ចេកវិទ្យាក្នុងកិច្ចការពារកុមារលើប្រព័ន្ធអនឡាញ" នៅពីថ្ងៃទី ២៨ ខែមិថុនា ដោយមានការចូលរួមពីតំណាងក្រសួងស្ថាប័នពាក់ព័ន្ធ ក្រុមហ៊ុនបច្ចេកវិទ្យាតំណាងអង្គការយូនីសេហ្វ និងអង្គការក្រៅរដ្ឋាភិបាលប្រមាណ ១៥០ រូប។

អគ្គនាយកបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ លោក នាង ម៉ៅ បានថ្លែងថា បន្ទាប់ពីអង្គសិក្ខាសាលានេះ ក្រុមការងារនឹងបន្តធ្វើការជាមួយក្រុមហ៊ុនបច្ចេកវិទ្យាបន្ថែមទៀត ដើម្បីសិក្សាស្វែងយល់អំពីលទ្ធភាពក្នុងការបញ្ជ្រាប និងដាក់បញ្ចូលគោលនយោបាយកិច្ចការពារកុមារតាមប្រព័ន្ធអនឡាញទៅក្នុងដំណើរការប្រតិបត្តិរបស់ក្រុមហ៊ុនបច្ចេកវិទ្យា និងអ្នកបង្កើតមាតិកាព័ត៌មាន។ លោកបន្តថា ការអនុវត្ត

គម្រោងនេះជាអន្តរាគមន៍បន្ទាន់មួយ ដើម្បីឆ្លើយតបទៅនឹងគ្រោះថ្នាក់ដែលកំពុងកើនឡើងយ៉ាងគំហុកលើបណ្តាញអ៊ីនធឺណិតចំពោះកុមារ និងជាការត្រៀមខ្លួនរបស់កម្ពុជាក្នុងការកសាងសេដ្ឋកិច្ច និងសង្គមឌីជីថល។ ការរំលោភបំពានកុមារតាមអនឡាញនៅកម្ពុជាកើនឡើងយ៉ាងច្រើនក្នុងពេលមានការរីករាលដាលនៃជំងឺកូវីដ ១៩ ដែលកុមារបានផ្លាស់ប្តូរជាច្រើនក្នុងរបៀបរបបរស់នៅ និងការសិក្សារបស់ពួកគេ។ លោកថា៖ «ករណីនៃការរាយការណ៍ពីការរំលោភបំពានផ្លូវភេទចំពោះកុមារលើបណ្តាញអ៊ីនធឺណិត ដែលកើតមាននៅមានក្នុងប្រទេសកម្ពុជា ចំនួនប្រមាណ ៤០ ម៉ឺនករណី គឺកើនលើស ឆ្នាំ ២០២០ ជាងទ្វេដង»។ លោកបានឱ្យដឹងថា ថ្មីៗនេះមានសកម្មភាពជួញដូររូបភាពអាសអាភាសបានកើតឡើងជាបន្តបន្ទាប់តាមបណ្តាញសង្គមនៅកម្ពុជា។ ខណៈកំណើនចរាចរណ៍លើករណីរំលោភបំពាន និងការផ្សព្វផ្សាយរូបភាពអាសអាភាសរបស់កុមារលើអ៊ីនធឺណិតផងនោះ ក្រុមហ៊ុនបច្ចេកវិទ្យាខ្នាតធំៗជាច្រើនលើសកលលោកបាននិងកំពុងទប់ស្កាត់ដោយប្រើប្រព័ន្ធបច្ចេកវិទ្យារបស់ខ្លួន ដូចជា ការប្រើប្រាស់ប្រព័ន្ធបញ្ញានិម្មិត ដើម្បីពិនិត្យលើរូបភាព និងកំណត់អត្តសញ្ញាណជនរងគ្រោះ ជនល្មើស និងទីតាំងជាដើម។ លោកថា៖ «ត្រង់ចំណុចនេះការចូលរួមរបស់វិស័យឯកជន ជាពិសេសក្រុមហ៊ុនបច្ចេកវិទ្យា និងអាណាព្យាបាលមានសារៈសំខាន់ណាស់ក្នុងការទប់ស្កាត់ការរីករាលដាលនៃករណីរំលោភបំពានផ្លូវភេទលើកុមារ និងការចូលរួមការពារជនរងគ្រោះ»។

លោក Benjamin Wildfire តំណាងអង្គការយូនីសេហ្វប្រចាំកម្ពុជាបានថ្លែងថា អង្គការយូនីសេហ្វបានសិក្សាលើការរំលោភបំពានកុមារតាមប្រព័ន្ធអនឡាញនៅប្រទេសចំនួន ៤ ក្នុងតំបន់អាស៊ានក្នុងនោះមានកម្ពុជាផងដែរ កាលពីឆ្នាំ ២០១៩។ លោកបន្តថា ភាគច្រើននៃកុមារបានប្រើបណ្តាញសង្គម សម្រាប់ប្រាស្រ័យទាក់ទងសម្រាប់ការកម្សាន្ត និងការសិក្សាជាដើម ហើយកុមារទាំង ២ ភេទដែលប្រើអ៊ីនធឺណិតនោះត្រូវបានជនមិនស្គាល់មុខផ្ញើរូបអាសអាភាស វីដេអូ និងមធ្យោបាយផ្សេងៗទាក់ទងការរំលោភបំពានផ្លូវភេទ។ ជាងនេះទៀត ហានិភ័យនេះបានកើនឡើងក្នុងពេលមានកូវីដ ១៩ ដោយសារកុមារប្រើពេលលើអនឡាញសម្រាប់រៀនសូត្រ។ លោកថា៖ « យ៉ាងណាក៏ដោយ គ្រប់ភាគីពាក់ព័ន្ធទាំងអស់មិនថា វិស័យឯកជន រដ្ឋ អង្គការក្រៅរដ្ឋាភិបាលត្រូវតែបន្តសហការធ្វើការជាមួយគ្នា ដើម្បីឱ្យកុមារទទួលបានអត្ថប្រយោជន៍ពីការប្រើប្រាស់អ៊ីនធឺណិតប្រកបដោយសុវត្ថិភាព ជាពិសេសរដ្ឋាភិបាលត្រូវតែមានវិធានការឆ្លើយតបឱ្យទាន់ពេលវេលា»។

លោក ជុន វ៉ាត រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍បានលើកឡើងថា ការគិតគូរការពារកុមារលើប្រព័ន្ធអនឡាញមានសារៈសំខាន់សម្រាប់សង្គមកម្ពុជាបច្ចុប្បន្ន និងអនាគត ហើយស្ថិតក្នុងបរិបទជំងឺកូវីដ ១៩ និងការបិទសាលា កុមារកម្ពុជាជាង ៣ លាននាក់មានតម្រូវការប្រើប្រព័ន្ធអនឡាញសម្រាប់ការរៀនសូត្រកម្សាន្ត ការប្រាស្រ័យទាក់ទងគ្នា។ លោកថា៖ «ស្របពេលជាមួយគ្នានេះហានិភ័យនៃប្រព័ន្ធអនឡាញ និងការគំរាមកំហែង និងការរំលោភបំពានផ្លូវភេទចំពោះកុមារមានចំនួនកើនឡើងគួរឱ្យបារម្ភដែលទាមទារឱ្យមានកិច្ចអន្តរាគមន៍ជាបន្ទាន់ និងការគិតគូរយុទ្ធសាស្ត្រ សម្រាប់រយៈពេលវែងបន្ថែមទៀត»។ ក្រុមហ៊ុនបច្ចេកវិទ្យា និងអ្នកមានឥទ្ធិពលលើបណ្តាញសង្គមដែលបានចូលរួមក្នុងសិក្ខាសាលានេះបានថ្លែងថា ពួកគេនឹងប្រើវេទិកានេះ ដើម្បីចែករំលែកបន្តលើប្រព័ន្ធអនឡាញ និងបង្កើតមាតិកាផ្សេងៗ ដើម្បីបញ្ជ្រាបការយល់ដឹងបន្ថែមដល់សាធារណជនឱ្យចូលរួមទប់ស្កាត់។

អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិ ដើម្បីកុមារ លោកស្រី សម្បត្តិ សុគន្ធា បានថ្លែងថា លោកស្រីពិតជាមានមោទនភាព ដោយសាររឿងកុមារនេះមានផ្នែកពាក់ព័ន្ធចូលរួមទប់ស្កាត់ ក្នុងនោះរួមទាំងពីវិស័យឯកជនថែមទៀត។ លោកស្រីបន្តថា៖ «មានន័យថា ការខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាល ជាពិសេសក្រុមប្រឹក្សា

ជាតិ ដើម្បីកុមារបានធ្វើការងារនេះច្រើនទាក់ទងការរំលោភផ្លូវភេទអនឡាញរហូតយើងមានក្រុមការងារបច្ចេកទេសអន្តរក្រសួងធ្វើការលើរឿងនេះ និងភាគីពាក់ព័ន្ធ»។

## បង្ក្រាបហាងកោសជប់ និងម៉ាស្សា 666 បម្រើសេវាផ្លូវភេទ ឃាត់ខ្លួនថៅកែ២នាក់

https://kohsantepheapdaily.com.kh/ ភ្នំពេញ៣០ ខែ មិថុនា ឆ្នាំ ២០២២ ម៉ោង ០៩:២៥

រាជធានីភ្នំពេញ ៖ ផ្ទះបើកបម្រើសេវាផ្លូវភេទ ជ្រកក្រោមស្លាកកោសជប់ និងម៉ាស្សា យីហោ៦៦៦ ត្រូវបានកម្លាំងនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការនគរបាលជាតិចុះបង្ក្រាបដោយឃាត់ខ្លួនថៅកែ២នាក់ប្ដីប្រពន្ធ និងនាំខ្លួន ស្ត្រីម៉ាស្សាចំនួន៣នាក់ទៅសាកសួរនៅក្នុងនោះមានអនីតិជនម្នាក់។ ការឆែកឆេរ និងបង្ក្រាបផ្ទះម៉ាស្សាខាងលើនេះបានធ្វើឡើងកាលពីវេលាម៉ោងប្រមាណ៩និង៣០នាទីយប់ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២២ នៅផ្ទះកោសជប់ម៉ាស្សាយីហោ៦៦៦ ស្ថិតនៅផ្ទះលេខ០៧A ផ្លូវ ជាតិលេខ៥ ក្នុងក្រុម៣ ភូមិឡកំបោរ សង្កាត់ស្វាយប៉ាក ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

ប្រតិបត្តិការចុះបង្ក្រាបករណីខាងលើនេះ ដឹកនាំដោយលោកឧត្តមសេនីយ៍ទោ សំបូរ មាណ្ណារិទ្ធ អនុប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការនគរបាលជាតិនិងមានការសម្របសម្រួលពីលោក ម៉ុត ដារ៉ា ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញព្រមទាំងមានការចូលរួមសហការណ៍ពីការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននៃស្នងការនគរបាលរាជធានីភ្នំពេញនិង នគរបាលមូលដ្ឋានផងដែរ។

ថៅកែហាង២នាក់ប្ដីប្រពន្ធ ដែលត្រូវឃាត់ខ្លួន ត្រូវបានសមត្ថកិច្ច អោយដឹងថា ឈ្មោះចូច ជឿន អាយុ២៩ឆ្នាំ ជាប្ដី និងប្រពន្ធឈ្មោះហន សុភានី អាយុ៤១ឆ្នាំ ។ អ្នកទាំង២នាក់ស្នាក់នៅកន្លែងកើតហេតុ ខាងលើ ។

តាមនគរបាលអោយដឹងថា ផ្ទះខាងលើ បានបើកដំណើរការកោសជប់និងម៉ាស្សាហើយលួចបម្រើសេវាផ្លូ.វភេ.ទ ដោយមានការស្រាវពីកម្លាំងនគរបាលជំនាញសមត្ថកិច្ច ក៏បានសុំគោលការពីព្រះរាជអាជ្ញាចុះឆែកឆេរ បង្ក្រាបតែម្ដង ។ តាមសមត្ថកិច្ចអោយដឹងថា បន្ទប់ចំនួន ៤ត្រូវកម្លាំងសមត្ថកិច្ចចម្រុះឆែកឆេរ រកឃើញវត្ថុតាង មានស្រោមអនាម័យ ប្រើរួច និងមិនទាន់ប្រើជាច្រើន ។ បន្ទាប់ពីបញ្ចប់ការឆែកឆេរ សមត្ថកិច្ចបានឃាត់ខ្លួន ថៅកែហាង២នាក់ប្ដីប្រពន្ធ និងនាំខ្លួន ស្ត្រីកោសជប់បម្រើសេវាកម្មផ្លូ.វភេ.ទចំនួន ៣នាក់និងដកហូតវត្ថុតាងមួយចំនួន បញ្ជូនទៅកាន់នាយកដ្ឋានប្រឆាំងការជួ.ញដូរមនុស្ស និងការពារអនីតិជនដើម្បីសាកសួរនិងចាត់ការតាមច្បាប់ ។ ដោយឡែក ផ្ទះខាងលើត្រូវបានគណៈកម្មការចម្រុះបិទបណ្ដោះអាសន្ន៕

## លោកស្រីអភិបាលរងខេត្តស្វាយរៀងៈរៀងរាល់ឆ្នាំមានមនុស្សរាប់សែនរាប់លាននាក់ត្រូវបានបំផ្លាញដោយឧក្រិដ្ឋជនជួញដូរមនុស្សនៅគ្រប់ទីកន្លែងក្នុងពិភពលោក

http://nokorwatnews.com/ 29/06/2022

ខេត្តស្វាយរៀង៖ លោកស្រី ឯក សុវណ្ណភារៈ អភិបាលរងខេត្ត ជាតំណាងលោក ម៉ែន វិបុល អភិបាលនៃគណៈអភិបាលខេត្តស្វាយរៀង បានមានប្រសាសន៍ថា រៀងរាល់ឆ្នាំមានមនុស្សរាប់សែនរាប់លាននាក់ ត្រូវបានបំផ្លាញដោយឧក្រិដ្ឋជនជួញដូរមនុស្សនៅគ្រប់ទីកន្លែងក្នុងពិភពលោក ។ លោកស្រីមានប្រសាសន៍បែបនេះគឺក្នុងឱកាសដែលលោកស្រីអញ្ជើញជាអធិបតីក្នុងវេទិកាផ្សព្វផ្សាយអង្គសាសនា ស្ដីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្រោមប្រធានបទ "រួមគ្នាបញ្ឈប់ការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចលើគ្រប់រូបភាព" នាព្រឹកថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២២។

ក្នុងឱកាសនោះក៏មានព្រះវិសុទ្ធិញាណ មុំ សយ ព្រះរាជាគណៈថ្នាក់កិត្តិយស និងជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសង្ឃរាជ នៃព្រះរាជាណាចក្រកម្ពុជានិងលោកទីវសុភា ប្រធានមន្ទីរធម្មការនិងសាសនាខេត្ត លោកស្រីប្រធានអនុប្រធានមន្ទីរពាក់ព័ន្ធនៃក្រុមការងារទាំង៦ និងលោក លោកស្រីតំណាងអង្គការដៃគូជាច្រើនអង្គ/នាក់និមន្តនិងអញ្ជើញចូលរួមផងដែរ។

លោកស្រីបន្តថា នេះជាការបង្ហាញឱ្យឃើញពីការរួបរួមគ្នាក្នុងការកសាងសេចក្តីសុខរមនាវវាងសាសនា នឹងសាសនា។ ទន្ទឹមនេះក៏ដើម្បីបង្ហាញឱ្យឃើញពីតួនាទីយ៉ាងសំខាន់របស់ថ្នាក់ដឹកនាំសាសនាទាំងឡាយក្នុងការផ្សព្វផ្សាយអប់រំ និងផ្តល់ចំណេះដឹងដល់ប្រជាពលរដ្ឋអំពីសីលធម៌ក្នុងការរស់នៅជៀសវាងការរំលោភបំពាន ការកេងប្រវ័ញ្ចលើមនុស្សគ្រប់រូប ព្រមទាំងចូលរួម ទប់ស្កាត់និងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

រាជរដ្ឋាភិបាលកម្ពុជាដែលដឹកនាំដោយ សម្តេចតេជោ ហ៊ុន សែន បានប្រឹងប្រែង អស់ពីកម្លាំងកាយចិត្តធ្វើការអប់រំផ្សព្វផ្សាយដល់សិស្សនិស្សិត និងប្រជាពលរដ្ឋឱ្យបានយល់ដឹងអំពីកលល្បិចរបស់ជនល្មើសជួញដូរមនុស្ស និងផលប៉ះពាល់ក្នុងការធ្វើទេសន្តរប្រវេសន៍ដោយប្រថុយប្រថានដែលអាចកើតមានគ្រោះថ្នាក់ជាយថាហេតុ។

ក្នុងនោះក្រសួងពាក់ព័ន្ធរួមជាមួយអាជ្ញាធរ សមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានបានដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញការផ្សព្វផ្សាយ ឱ្យបានដល់គ្រប់ស្រទាប់នៃយុវជន សិស្សនិស្សិត ប្រជាពលរដ្ឋនៅជនបទនិងតាមតំបន់ដែលមានសេវាកម្សាន្តឱ្យបានយល់ដឹងជ្រួតជ្រាប អំពីគ្រប់ល្បិចកល របស់ជនខិលខូចដែលឆ្លៀតឱកាសប្រើគ្រប់មធ្យោបាយដើម្បីអូសទាញប្រជា ពលរដ្ឋឱ្យធ្លាក់ចូលក្នុងអន្ទាក់គ្រោះថ្នាក់នៃអំពើជួញដូរមនុស្ស ។

លោកស្រីបន្តថា យើងទាំងអស់គ្នា បានដឹងច្បាស់ហើយថា អំពើជួញដូរមនុស្សជាប្រភេទឧក្រិដ្ឋកម្មឆ្លងដែនដែលប្រកបដោយគ្រោះថ្នាក់ចំពោះមនុស្សគ្រប់វ័យគ្រប់ភេទក្នុងសង្គម គ្រោះថ្នាក់ជាញឹកញាប់ត្រូវបានរកឃើញក្នុងចំណោមអ្នកធ្វើចំណាកស្រុក ឬទេសន្តរប្រវេសន៍ ដែលស្វែងរកការងារនិងប្រាក់ចំណូល ដែលនៅឆ្ងាយពីទីកន្លែងដែលខ្លួនរស់នៅ។ ជនល្មើសបានរកគ្រប់ល្បិចកលដ៏ស្មោកគ្រោក ពង្រាយបណ្តាញធ្វើសកម្មភាពកេងប្រវ័ញ្ចជនរងគ្រោះនៅគ្រប់ដំណាក់កាលទាំងដោយផ្ទាល់ និង ប្រយោលតាមរយៈបណ្តាញទំនាក់ទំនងអនឡាញ (Online) ឬតាមបច្ចេកវិទ្យាទំនើប ដែលប្រជាពលរដ្ឋ ជាពិសេសយុវវ័យ កុមារ និងមនុស្សពេញវ័យនិយមប្រើប្រាស់ គឺទូរស័ព្ទដៃនិងប្រព័ន្ធអ៊ិនធើណេត ៕